# ៣. ការអធិប្បាយអំពីគំរោង

## ៣-១ សាវតាក្រុមហ៊ុន

២៨. ក្រុមហ៊ុន **អេច អិល អេច អេគ្រីខលឈ័រ (ខេមបូឌា)ខូអិលធីឌី** ជាសហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត។ ក្រុមហ៊ុននេះបានចុះបញ្ជីការនៅក្រសួងពាណិជ្ជកម្ម ជាមួយនឹងការដាក់ដើមទុនចុះបញ្ជីការដំបូងចំនួន២០.០០០.០០០រៀល។ ក្រុមហ៊ុនគ្រោងវិនិយោគនូវទឹកប្រាក់ចំនួន ៤០.០០០.០០០.ដុល្លាអាមេរិក ដើម្បីចំណាយលើការដាំដុះដំបូង (ការសាងសង់សំណង់ស៊ីវិល, ចំណាយលើការទិញមធ្យោបាយផលិតកម្ម និង ចំណាយប្រតិបត្តិការអាជីវកម្ម) ក្នុងដំណាក់កាល១០ឆ្នាំដំបូង នៃការអភិវឌ្ឍន៍ចំការកសិដ្ឋានដំណាំ កសិ-ឧស្សាហកម្មនេះ។

## ៣-២ លិខិតបទដ្ឋានច្បាប់របស់គំរោង

២៩. ឯកសារគោលការណ៍ច្បាប់ដែលក្រុមហ៊ុន **អេច អិល អេច អេគ្រីខលឈ័រ (ខេមបូឌា) ខូអិលធីឌី** (HLH Agriculture (CAMBODIA) CO., LTD) បានទទួលពីរាជរដ្ឋាភិបាលកម្ពុជា រួមមាន :

ក- លិខិតលេខ ១៤៤ ស.ជ.ណ ចុះថ្ងៃទី ២៧ ខែ មិនា ឆ្នាំ ២០០៩ របស់ក្រសួង បរិស្ថាន ស្តីពីវិនិយោគលើការដាំដំណាំកសិ-ឧស្សាហកម្ម លើផ្ទៃដី ៩.៩៨៥ ហិកតា ស្ថិតនៅក្នុងតំបន់ប្រើប្រាស់ដោយចេរភាពនៃដែនជំរកសត្វព្រៃភ្នំឱរ៉ាល់ ខេត្តកំពង់ស្ពឺ សំរាប់វិនិយោគដាំដំណាំពោត និងសាងសង់រោងចក្រកែច្នៃ។ របស់ក្រុមហ៊ុន **អេច អិល អេច អេគ្រីខលឈ័រ (ខេមបូឌា) ខូអិលធីឌី** ស្ថិតនៅក្នុង ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ (ដូចមានជូនភ្ជាប់ក្នុង ឧបសម្ព័ន្ធ២-៣)។

ខ- លិខិតលេខ ៤០០ សជណ ចុះថ្ងៃទី ០៥ ខែ មិនា ឆ្នាំ ២០០៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី គឺរាជរដ្ឋាភិបាលបានយល់ព្រមតាមសំណើររបស់ក្រសួងបរិស្ថានឱ្យក្រុមហ៊ុន **អេច អិល អេច អេគ្រីខលឈ័រ (ខេមបូឌា) ខូអិលធីឌី** ដើម្បីវិនិយោគដាំដំណាំកសិក-ឧស្សាហកម្ម លើផ្ទៃដីសរុប ៩.៩៨៥ ហិកតា ស្ថិតនៅក្នុង ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ។ (មានជូនភាប់ក្នុង ឧបសម្ព័ន្ធ២-១)។

គ- លិខិតលេខ ០៩៣ ប.ស្ថ ចុះថ្ងៃទី ២៧ ខែ មិនា ឆ្នាំ ២០០៩ របស់ក្រសួង បរិស្ថាន ស្តីពីសំណើសុំឈូសឆាយព្រៃប្រទលដីវិនិយោគសំរាប់ដាំដំណាំកសិ-ឧស្សាហកម្ម លើផ្ទៃដីចំនួន

Draft

៩៩៨៥ ហិកតា ស្ថិតនៅក្នុងតំបន់ប្រើប្រាស់ដោយចីរភាពនៃដែនជំរកសត្វព្រៃភ្នំឱរ៉ាល់ ខេត្តកំពង់ស្ពឺ របស់ក្រុមហ៊ុន **អេច អិល អេច អេគ្រីខលឈ័រ (ខេមបូឌា) ខូអិលធីឌី**(ឧបសម្ព័ន្ធ២-២)។

ឃ-លិខិតលេខ ៤៨ អ.ន.ក្រ.ប.ក ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០០៩ ការកំណត់តំបន់ប្រើប្រាស់លើផ្ទៃដីចំនួន ៩៩៨៥ ហិកតា ក្នុងដែនជំរកសត្វព្រៃភ្នំឱរ៉ាល់ និងការធ្វើអនុប្រយោគដីសម្បទានសាធារណៈរបស់រដ្ឋ មកជាសម្បត្តិឯកជនរបស់រដ្ឋ។(មានជូនភ្ជាប់ក្នុងឧបសម្ព័ន្ធ២-៤)

## ៣-៣ ប្រវត្តិរបស់ដីសម្បទាន

៣០. តំបន់ដីសម្បទានសំរាប់ធ្វើវិនិយោគលើវិស័យកសិ-ឧស្សាហកម្ម (ពោត) ស្ថិតនៅក្នុងស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ដែលមានចម្ងាយប្រមាណ ៦០-៧០ គីឡូម៉ែត្រពីទីរួមខេត្ត ហើយផ្លូវគមនាគមន៍ដើម្បីធ្វើដំណើរទៅតំបន់នោះមានលក្ខណៈលំបាក។ ហើយរហូតមកដល់សព្វថ្ងៃនេះ ធនធានធម្មជាតិកំពុងបាត់បង់ និងសកម្មភាពសេដ្ឋកិច្ចក្នុង និងជុំវិញតំបន់ដីសម្បទាន ក៏ពុំសូវមានសកម្មភាពខ្លាំងក្លាដែរ។

៣១. ក្នុងគោលបំណងចូលរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចកសិកម្ម ក៏ដូចជាជួយថែរក្សាធនធានដីជាតិដីក្នុងតំបន់ ក្រុមហ៊ុនយើងខ្ញុំបានពិនិត្យលទ្ធភាពវិនិយោគ ហើយបានស្នើសុំដីសម្បទានពីរាជរដ្ឋាភិបាលកម្ពុជា សំរាប់ផលិតកម្មដាំដុះដំណាំកសិក-ឧស្សាហកម្ម(ពោត) លើផ្ទៃដី ចំនួន ៩.៩៨៥ ហិកតា នៅក្នុងស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ។ ក្រសួងបរិស្ថានបានចាត់មន្ត្រីជំនាញ សហការជាមួយមន្ត្រីជំនាញខេត្ត ស្រុក ចុះពិនិត្យជាក់ស្តែងដល់ទីតាំងស្នើសុំដែលជាលទ្ធផលគឺចំនួន ៩.៩៨៥ ហិកតា សំរាប់ផ្តល់ជូនក្រុមហ៊ុនធ្វើអាជីវកម្មបាន។

Draft

៣២. បន្ទាប់មកក្រសួងបរិស្ថានបានលើកសំណើរសុំការសំរេចជាគោលការណ៍ពីរាជរដ្ឋាភិបាល ដើម្បីផ្តល់ជូនក្រុមហ៊ុនធ្វើវិនិយោគលើផ្ទៃដី ៩.៩៨៥ ហិកតា នេះ។ រាជរដ្ឋាភិបាលក៏បានឯកភាពផ្តល់ឱ្យក្រុមហ៊ុនធ្វើការវិនិយោគ និងបានស្នើសុំសិទ្ធប្រទានពីរាជរដ្ឋាភិបាល ដើម្បីចុះកិច្ចសន្យាជាមួយក្រុមហ៊ុន។ រាជរដ្ឋាភិបាលបានប្រគល់សិទ្ធិប្រទានជូនឯកឧត្តមទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងបរិស្ថាន ដើម្បីចុះហត្ថលេខាជាមួយក្រុមហ៊ុន តាមលិខិតលេខ ១៤៤ ស.ជ.ណ កស.បស្ក ចុះថ្ងៃទី ២៧ ខែ មិនា ឆ្នាំ ២០០៩ និងបានចុះហត្ថលេខាលើកិច្ចសន្យាជាមួយក្រសួង បរិស្ថាន នៅថ្ងៃទី ២៧ ខែ មិនា ឆ្នាំ ២០០៩។

## ៣-៤ ទីតាំង និងទំហំដីសម្បទាន

៣៣. ដីសម្បទានដែលក្រុមហ៊ុន **អេច អិល អេច អេហ្គ្រីខលឈ័រ.(ខេមបូឌា) ខូអិលធីឌី** ទទួលបានការប្រទានសិទ្ធិពី រាជរដ្ឋាភិបាល ដើម្បីធ្វើការអភិវឌ្ឍន៍ដំណាំកសិ-ឧស្សាហកម្មនេះមានទំហំ ៩៩៨៥ហិកតា មាន

ទីតាំងស្ថិតក្នុង ភូមិសាស្ត្រឃុំត្រពាំងជោ និងឃុំសង្កែសាទប ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ។ ដីសម្បទាននេះអាចចូលពី ភូមិដំបងវេញ ភូមិច្រកទៀក ភូមិជំនាប់ និងភូមិត្រាងពង្រ ដែលមានចំងាយ៣-៥គីឡូម៉ែត្រភាគខាងកើតនៃដីសម្បទាន ស្ថិតនៅតាមដងផ្លូវទៅភូមិដំបងវេញ ក្នុងខេត្តកំពង់ស្ពឺ ដោយមាន ស្ថានភាពផ្លូវលំបាកក្នុងការធ្វើដំណើរ។

៣៤. ទីតាំងដីសម្បទានរបស់ក្រុមហ៊ុន(ដូចមានផែនទីតំបន់ភ្ជាប់មកជាមួយក្នុងឧបសម្ព័ន្ធ១ផែនទី១-៣) មានកូអរដោនេបង្ហាញដូចខាងក្រោម :

| ចំណុចគោល ព្រំដីសម្បទាន | ចំណុចអាប់ស៊ីស (X) | ចំណុចអរដោនេ (Y) | ចំណុចគោល ព្រំដីសម្បទាន | ចំណុចអាប់ស៊ីស (X) | ចំណុចអរដោនេ (Y) |
|---|---|---|---|---|---|
| 1 | ៤០២២៤២ | ១៣១១៦៣៤ | 55 | ៣៩៧០៦៧ | ១៣០៥១៥៧ |
| 2 | ៤០២២២១ | ១៣០៧៦២៣ | 56 | ៣៩៧០១១ | ១៣០៥២៨០ |
| 3 | ៤០៤០២៦ | ១៣០៦០៩៤ | 57 | ៣៩៧០៧៣ | ១៣០៥៤៣៤ |
| 4 | ៤០៤០១០ | ១៣០១៣០៥ | 58 | ៣៩៧០៥៤ | ១៣០៥៥២៤ |
| 5 | ៤០៣២៣៧ | ១៣០១២៧៩ | 59 | ៣៩៦៩៥១ | ១៣០៥៥៧០ |
| 6 | ៤០៣២០០ | ១៣០០៧៤១ | 60 | ៣៩៦៨៩២ | ១៣០៥៤៣៤ |
| 7 | ៤០៤០២៨ | ១៣០០១៣៨ | 61 | ៣៩៦៧៣៧ | ១៣០៥៤៣៩ |
| 8 | ៤០៤០១៦ | ១២៩៧០១៨ | 62 | ៣៩៦៧២៥ | ១៣០៥៥៧២ |
| 9 | ៤០៣៨៦៨ | ១២៩៦៨០០ | 63 | ៣៩៦៦១២ | ១៣០៥៦២៨ |
| 10 | ៤០៤០១២ | ១២៩៦៧៥៣ | 64 | ៣៩៦៤១៧ | ១៣០៥៤៦៤ |
| 11 | ៤០៤០១០ | ១២៩៤៩៧៨ | 65 | ៣៩៦២៣៦ | ១៣០៥៣៨០ |
| 12 | ៤០៣៨២២ | ១២៩៤៨៨៦ | 66 | ៣៩៦២៣៥ | ១៣០៥២៣៣ |
| 13 | ៤០៤០១២ | ១២៩៤៧០៦ | 67 | ៣៩៦១៣០ | ១៣០៤៩៧២ |
| 14 | ៤០៤០១៤ | ១២៩៤២៤៤ | 68 | ៣៩៥៩៨៨ | ១៣០៤៨៤០ |
| 15 | ៤០៣៦៥៤ | ១២៩៤០៩១ | 69 | ៣៩៥៩៧៣ | ១៣០៤៨៣៦ |
| 16 | ៤០៣២១២ | ១២៩៤២១០ | 70 | ៣៩៥៤៦៤ | ១៣០៤៨៤៤- |
| 17 | ៤០៣០៦៤ | ១២៩៤៤៩៩ | 71 | ៣៩៥២៧៣ | ១៣០៤៧៨២ |
| 18 | ៤០២៨៨០ | ១២៩៤៥១៨ | 72 | ៣៩៥១៦១ | ១៣០៤៩៥៩ |
| 19 | ៤០២៤៣៩ | ១២៩៤៤៣៧ | 73 | ៣៩៥១៧៥ | ១៣០៥១៣៩ |

| | | | | | |
|---|---|---|---|---|---|
| 20 | ៤០២០០៩ | ១២៩៤៥៤៨ | 74 | ៣៩៥០០៩ | ១៣០៥៤០៧ |
| 21 | ៤០០៦៧១ | ១២៩៥៤៧៤ | 75 | ៣៩៤៧៦៨ | ១៣០៥៤៩០ |
| 22 | ៣៩៩០០៩ | ១២៩៥៧៣៣ | 76 | ៣៩៤៦១៣ | ១៣០៥៧០២ |
| 23 | ៣៩៨៩៩៨ | ១២៩៦៤០៥ | 77 | ៣៩៤៤៥៤ | ១៣០៥៨៨៤ |
| 24 | ៣៩៩៣១៦ | ១២៩៦៩៦០ | 78 | ៣៩៤៣១៥ | ១៣០៥៩៩៣ |
| 25 | ៣៩៩៨២៩ | ១២៩៧៣៦៣ | 79 | ៣៩២៩០២ | ១៣០៥៩៩៣ |
| 26 | ៤០០១១១ | ១២៩៧៤៦០ | 80 | ៣៩២៩៣៩ | ១៣០៧១៩២ |
| 27 | ៤០០០៨១ | ១២៩៧៦៩៦ | 81 | ៣៩២៩៧៩ | ១៣០៧២៣៣ |
| 28 | ៣៩៩៨៥៣ | ១២៩៧៩៧២ | 82 | ៣៩៣១៦២ | ១៣០៧១៩៩ |
| 29 | ៣៩៩៤៨៥ | ១២៩៨១៥៤ | 83 | ៣៩៣២៧៩ | ១៣០៧២៦០ |
| 30 | ៣៩៩២២១ | ១២៩៨៣៦៨ | 84 | ៣៩៣៣៣២ | ១៣០៧៣៥២ |
| 31 | ៣៩៩០៨៤ | ១២៩៨៥៨៤ | 85 | ៣៩៣៣៤៦ | ១៣០៧៤៣ |
| 32 | ៣៩៨៨៥០ | ១២៩៩០០៨ | 86 | ៣៩៣៥០៥ | ១៣០៧៥៧៤ |
| 33 | ៣៩៩០០៩ | ១២៩៩១៧២ | 87 | ៣៩៣៤៧១ | ១៣០៧៦៧៥ |
| 34 | ៣៩៩០១៤ | ១៣០០០១៤ | 88 | ៣៩៣៣២៩ | ១៣០៧៦៨៤ |
| 35 | ៤០០៣៩០ | ១២៩៩៩៩៨ | 89 | ៣៩៣០៦៥ | ១៣០៧៦០៦ |
| 36 | ៤០០៤៤២ | ១២៩៩៨៨២ | 90 | ៣៩២៩២៩ | ១៣០៧៥២៧ |
| 37 | ៤០១០៨៧ | ១២៩៩៨៤៥ | 91 | ៣៩២៩៨២ | ១៣១១៦៤៥ |
| 38 | ៤០១០៨២ | ១៣០០៣៩០ | 92 | ៣៩៣២៥៧ | ១៣១៣០៣០ |
| 39 | ៤០០៧៣៦ | ១៣០០៧៣០ | 93 | ៣៩២៦៣១ | ១៣១៣៤៦២ |
| 40 | ៤០០៤០៦ | ១៣០០៦២៨ | 94 | ៣៩៣១១៥ | ១៣១៤០១០ |
| 41 | ៤០០៣៩៥ | ១៣០២០៦២ | 95 | ៣៩៣១៧៣ | ១៣១៥៤០៩ |
| 42 | ៤០០៧៦៦ | ១៣០២១៨៣ | 96 | ៣៩៤០៨៨ | ១៣១៥៩៩៦ |
| 43 | ៤០០៩៨៤ | ១៣០២២៨៣ | 97 | ៣៩៥២៤៩ | ១៣១៥៩៩៨ |
| 44 | ៤០១០៣០ | ១៣០២៧៤២ | 98 | ៣៩៥២៣៦ | ១៣១៣៩៧ |
| 45 | ៤០០៦៤២ | ១៣០២៧០៨ | 99 | ៣៩៥៥៧១ | ១៣១៣០៤៩ |
| 46 | ៤០០២៨៤ | ១៣០៤២៣៧ | 100 | ៣៩៦៥៧៧ | ១៣១២៤៥០ |

Draft

| | | | | | |
|---|---|---|---|---|---|
| 47 | ៤០០០៤១ | ១៣០៤២៨៤ | 101 | ៣៩៦៦០៣ | ១៣០៩២៩៧ |
| 48 | ៤០០១២០ | ១៣០៥១៥២ | 102 | ៣៩៧៣៩០ | ១៣០៨៨៣៩ |
| 49 | ៣៩៨៨៦១ | ១៣០៤៤០១ | 103 | ៣៩៨៩៣១ | ១៣០៩១៣៥ |
| 50 | ៣៩៨២០៧ | ១៣០៤៥៣៤ | 104 | ៣៩៩៤៤៧ | ១៣១០១៧៤ |
| 51 | ៣៩៧៩៨៨ | ១៣០៤៤៦៤ | 105 | ៤០០៣៩៤ | ១៣១០២៤៤ |
| 52 | ៣៩៧៤២០ | ១៣០៤៧៩១ | 106 | ៤០១០០០ | ១៣១០៥០៩ |
| 53 | ៣៩៧៣៣៦ | ១៣០៤៨៨៣ | 107 | ៤០១៤១៣ | ១៣១១៦៥០ |
| 54 | ៣៩៧២០០ | ១៣០៥១២០ | | | |

**៣៥.** យោងតាមរូបភាពផ្កាយរណប FA GIS Dataset 2006 បានបង្ហាញថា នៅលើផ្ទៃដីចំនួន ៩៩៨៥ ហិកតានេះ សារព័ន្ធរុក្ខជាតិត្រូវបានបែងចែកទៅតាមប្រភេទ និងអនុប្រភេទព្រៃដូចជា: (១) ព្រៃល្បោះ ទំហំ ៨៨៥៤ហិកតា ស្មើនឹង៨៨.៦៧% (២) ព្រៃពាក់កណ្ដាលស្រោងទំហំ ៣៣១.៣ហិកតា ស្មើនឹង ៣.៣២% (៣) ព្រៃស្រោងទំហំ ៧៩២.៩ហិកតា ស្មើនឹង ៧.៩៤% (៤) ដីគ្មានព្រៃទំហំ ៦.៩ហិកតា ស្មើនឹង០.០៧ភាគរយ ។

**៣៦.** ការវាយតំលៃហេតុប៉ះពាល់បរិស្ថាននិងសង្គម តាមរយៈការអង្កេតលើលក្ខណៈអេកូឡូស៊ី និង សេដ្ឋកិច្ចសង្គម ត្រូវបានប្រព្រឹត្តទៅនៅទូទាំងតំបន់គំរោង ដោយការប្រើប្រាស់ផែនទីផ្កាយរណប FA GIS Dataset 2006 ជាផែនទីមូលដ្ឋានសំរាប់ការកំណត់អំពីប្រភេទព្រៃ និងការពិគ្រោះយោបល់ជាមួយសហគមន៍ មូលដ្ឋាន និងអាជ្ញាធរខេត្ត។ ជាមួយនឹងឯកសារយោងដូចបានរៀបរាប់ខាងលើ ទិន្នន័យនិងពត៌មានចាំបាច់ ទាំងអស់ត្រូវបានប្រមូលនៅតាមមូលដ្ឋាន ទៅតាមវិធីសាស្ត្រនានា ដូចបានកំណត់នៅក្នុងវិធីសាស្ត្រស្រាវជ្រាវ (ជំពូក ១-២) ។

## ៣-៥ ការរៀបចំគ្រប់គ្រងដីសម្បទាន

### ៣-៥-១ គោលបំណងនៃការធ្វើវិនិយោគដីសម្បទាន

**៣៧.** គោលដៅចំបងលើការវិនិយោគលើដីសម្បទាននេះ គឺសំដៅចូលរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចកសិកម្ម ប្រកបដោយនិរន្តរភាព និងជួយកាត់បន្ថយភាពក្រីក្រ របស់ប្រជាជនកម្ពុជាតាមរយៈ ការវិនិយោគស្តារ និង បង្កើនផលិតកម្មកសិកម្ម ដោយការអភិវឌ្ឍន៍ចំការពោត ដើម្បីលើកកំពស់ប្រសិទ្ធភាពសេដ្ឋកិច្ចនៃព្រៃរេចរិល កែលំអលំនឹងបរិស្ថានធម្មជាតិ ដោយការបង្កើតឡើងនូវចំការពោត និងការកែច្នៃផលិតផលពោត ។

Draft

៣៨. បណ្តាប្រទេសមួយចំនួននៅលើពិភពលោក ដូចជា គុយបា ថៃឡង់ ឥណ្ឌូណេស៊ី វៀតណាម បានធ្វើការដាំដុះពោត និងបានទទួលផលចំណេញពីការដាំដុះនេះគួរជាទីគាប់ចិត្ត ព្រោះពោតអាចយកមកកែច្នៃប្រើប្រាស់ធ្វើជាវត្ថុធាតុដើមបានច្រើនមុខ ។

៣៩. គោលបំណងលំអិត និងយូរអង្វែងនៃគំរោងវិនិយោគនេះមានដូចខាងក្រោម:

១- បង្កើនផលិតភាពពោតលើផ្ទៃដីព្រៃដែលត្រូវបានកាប់បំផ្លាញរេចរិល ក្នុងតំបន់ដីសម្បទាន តាមរយៈការអភិវឌ្ឍន៍ ការដាំដុះដំណាំពោត ជាលក្ខណៈកសិ-ឧស្សាហកម្ម ។

២- បង្កើតជាតំបន់បៃតង និងជួយទប់ទល់ការពារការហូរច្រោះដី បង្កើតអោយមានបរិស្ថានល្អ ធ្វើអោយមានលំនឹងបរិស្ថានធម្មជាតិក្នុងតំបន់ដីសម្បទាន ។

៣- រួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ បង្កើនប្រាក់ចំណូលដល់ប្រជាពលរដ្ឋ ពិសេសប្រជាកសិករ ដែលរស់នៅក្បែរតំបន់ដីសម្បទាន ក្នុងទិសដៅកាត់បន្ថយភាពក្រីក្រ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ។

៤- ជំរុញការកែច្នៃផលិតផលពោតសំរាប់ផ្គត់ផ្គង់តម្រូវការ ក្នុងស្រុក និង ធ្វើការនាំចេញទៅទីផ្សារអន្តរជាតិ ។ល ។

៥- បង្កើតអោយមានផលិតផលចេញពីពោត ដែលមិនទាន់មាននៅក្នុងប្រទេសកម្ពុជា និងណែនាំអោយវិនិយោគិនធំៗ ចាប់អារម្មណ៍ពីការវិនិយោគដាំពោតនៅកម្ពុជា ។

## ៣-៥-២ កម្មវត្ថុនៃការប្រើប្រាស់ដីសម្បទាន

៤០. កម្មវត្ថុនៃការរៀបចំប្រើប្រាស់ដីសម្បទានសំរាប់ធ្វើវិនិយោគ លើគំរោងបង្កើតកសិដ្ឋាន ដើម្បីអភិវឌ្ឍន៍ចំការដំណាំកសិ-ឧស្សាហកម្ម(ពោត) និងការកែច្នៃផលិតផលពោត គឺផ្តោតវិនិយោគលើប្រភេទផលិតកម្ម-អាជីវកម្ម ដូចខាងក្រោម:

- **ផលិតកម្មចំបង :** ដាំដំណាំពោតដែលមានលក្ខណៈជាចំការកសិ-ឧស្សហកម្មទ្រង់ទ្រាយធំ ដើម្បីបង្កើនផលិតកម្មពោត ។

- **ផលិតកម្មបន្ទាប់បន្សំ :** ដាំដុះដំណាំរដូវបន្ទាប់រដូវ បន្ទាប់បន្សំសំរាប់គំរបដី ដើម្បីជួយទប់ស្កាត់ការហូរច្រោះដី ។

Draft

- **ការសាងសង់ :** រោងចក្រកែច្នៃផលិតផលពោត និងសាងសង់ ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ក្នុងតំបន់សម្បទាន។

## ៣-៥-៣ ប្រព័ន្ធ និងទស្សនៈនៃការគ្រប់គ្រងដីសម្បទាន

៤១. ដោយមានការគាំទ្រពីរាជរដ្ឋាភិបាលកម្ពុជា ក្រុមហ៊ុនបានទទួលគោលការណ៍ឯកភាពអនុញ្ញាត អោយធ្វើការវិនិយោគលើផលិតកម្មដំណាំពោត ក្នុងតំបន់ដីសម្បទាននៃភូមិសាស្ត្រ ឃុំ ត្បិន ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ លើផ្ទៃដីសម្បទានសេដ្ឋកិច្ចសរុបចំនួន **៩.៩៨៥ ហិកតា** ដែលជាផ្ទៃដីសំរាប់ធ្វើអាជីវកម្ម-ផលិតកម្ម។

**៤២.** ដើម្បីឱ្យគំរោងវិនិយោគនេះដំណើរការប្រកបដោយជោគជ័យ ក្រុមហ៊ុនយើងខ្ញុំបានសំរេចរៀបចំ គំរោងផែនការមេ ដោយផ្អែកលើលក្ខណៈទីតាំងភូមិសាស្ត្រ និងស្ថានភាពដីនៃតំបន់សម្បទាន។ ទស្សនៈទាន របស់ក្រុមហ៊ុន **អេច អិល អេច អេគ្រ៉ីខលឈ័រ (ខេមបូឌា) ខូអិលធីឌី** ដែលបានសំរេចដាក់ទុនវិនិយោគនេះ គឺបណ្តាលមកពី :

- តំបន់ដីសម្បទាន មានលក្ខណៈអំណោយផលដល់ការដាំដុះ ដំណាំពោត និង ប្រភេទដំណាំកសិ-ឧស្សាហកម្មផ្សេងៗទៀត។
- រាជរដ្ឋាភិបាលកម្ពុជា មានការលើកទឹកចិត្តដល់ការវិនិយោគឯកជនភាវូបនីយកម្ម ពិសេសវិស័យ កសិកម្ម និងឧស្សាហកម្ម។
- មានកិច្ចសហប្រតិបត្តិការល្អរវាងប្រទេសជិតខាង និងព្រះរាជាណាចក្រកម្ពុជា និងមានព្រំប្រទល់ ប្រទេសជាប់គ្នា។
- កំលាំងពលកម្ម និងការចំណាយលើថ្លៃផលិតកម្ម មានកំរិតទាបជាងប្រទេសដទៃក្នុងតំបន់។
- ជួយធ្វើការអភិវឌ្ឍន៍តំបន់នេះ តាមរយៈផ្តល់មុខរបរ និងការងារដល់ប្រជាពលរដ្ឋ ដែលរស់ នៅក្បែរតំបន់ដីស្បទាន ផ្តល់បច្ចេកវិជ្ជា និងកសាងហេដ្ឋារចនាសម្ពន្ធ័ផ្សេងៗដូចជា ផ្លូវថ្នល់ ប្រពន្ធ័ស្រោចស្រព...។ល។ ក្នុងគោលបំណងរួមចំណែកជាមួយរដ្ឋាភិបាលកម្ពុជា ដើម្បីសំរេចនូវ គោលដៅក្នុងការកាត់បន្ថយភាពក្រីក្រ របស់ប្រជាពលរដ្ឋកម្ពុជា និងជំរុញកំណើនសេដ្ឋកិច្ចជាតិ។
- ដើម្បីរកប្រាក់ចំណូលជូនក្រុមហ៊ុន ដោយការធ្វើអាជីវកម្មមានលក្ខណៈបច្ចេកទេស និងគិតអំពី លំនឹងបរិស្ថាន ក៏ដូចជាផ្តល់ប្រាក់ចំណូលជូនដល់រាជរដ្ឋាភិបាលកម្ពុជា តាមរយៈការបង់ពន្ធអាករ ផ្សេងៗ និង បង្កើនប្រាក់ចំណូលប្រជាពលរដ្ឋកម្ពុជា។
- ផ្លាស់ប្តូរបទពិសោធន៍ និងបច្ចេកទេស ដែលមាននៅប្រទេសកម្ពុជា ជាមួយប្រទេសសាំងហ្គាពួរ។

Draft

- ក្រុមហ៊ុនមានទុនវិនិយោគ និងបទពិសោធន៍គ្រប់គ្រាន់ លើដំណាំពោតនៅប្រទេសសាំងហ្គាពួរ ម្យ៉ាងវិញទៀត ដើម្បីឈានដល់ការផ្លាស់ប្តូរបទពិសោធន៍បច្ចេកទេស លើវិស័យកសិកម្ម រវាងក្រុមអ្នកបច្ចេកទេសនៅកម្ពុជា។ល។

## ៣-៥-៤ ផែនការនៃការធ្វើអាជីវកម្ម និងប្រព្រឹត្តិកម្ម

### ៣-៥-៤-១ ផែនការបែងចែកផ្ទៃដីសំរាប់ផលិតកម្ម

៤៣. ការកំណត់ផែនការបែងចែកផ្ទៃដីផលិតកម្ម នឹងត្រូវផ្អែកទៅលើលទ្ធផលនៃការអង្កេតធ្វើសារពើភ័ណ្ឌព្រៃឈើធម្មជាតិដែលមាននៅសេសសល់ក្នុងតំបន់ដីសម្បទាន ដោយនឹងផ្តល់អោយនូវទិន្នន័យផ្ទៃដី ដែលក្រុមហ៊ុនអាចឈូសឆាយគំរប់ព្រៃធម្មជាតិ ដែលមិនមានតំលៃសេដ្ឋកិច្ច ដើម្បីដាំដុះពោតតាមផែនការដាំដុះ។

៤៤. ចំពោះផ្ទៃដីដែលមានគំរប់ព្រៃឈើធម្មជាតិនៅល្អ មានប្រសិទ្ធិភាពសេដ្ឋកិច្ច ក្រុមហ៊ុនបានសហការជាមួយក្រុមការងាររបស់ក្រសួង បរិស្ថាន លេខាធិការដ្ឋានបច្ចេកទេស សំរាប់សម្បទានដីសេដ្ឋកិច្ច និងក្រុមការងារខេត្តកំពង់ស្ពឺ បានចុះធ្វើការសិក្សារួចហើយ ដែលតំរូវអោយក្រុមហ៊ុនត្រូវតែថែរក្សាការពារ មិនធ្វើការឈូសឆាយដាំដុះឡើយ។ ក្រុមហ៊ុនសូមបញ្ជាក់ពីជំហរច្បាស់លាស់ និងរឹងមាំ របស់ក្រុមហ៊ុនលើការគ្រប់គ្រងធ្វើអាជីវកម្ម-ផលិតកម្ម ក្នុងតំបន់ដីសម្បទានដោយធ្វើយ៉ាងណាអោយការធ្វើអាជីវកម្ម-ផលិតកម្មក្នុងតំបន់ដីសម្បទាន ដោយធ្វើយ៉ាងណាឱ្យការធ្វើអាជីវកម្ម-ផលិតកម្មនេះ ប្រកបដោយនិរន្តរភាពរក្សាបានគំរបដីល្អប្រសើរ។

៤៥. យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៩ ក្រុមហ៊ុនបានស្នើសុំដីសម្បទានចំនួន **៩.៩៨៥ ហិកតា** និងតាមការចុះសិក្សាវាយតំលៃលើសំណើសុំរបស់ក្រុមហ៊ុន ក្រុមការងារក្រសួង បរិស្ថាន ក្រុមការងារលេខាធិការដ្ឋានបច្ចេកទេសសំរាប់សម្បទានដីសេដ្ឋកិច្ច និងក្រុមការងារ ខេត្តកំពង់ស្ពឺ ឃើញថាៈ គឺអាចអនុញ្ញាតឱ្យក្រុមហ៊ុនធ្វើវិនិយោគបានតែលើផ្ទៃដីចំនួន **៩.៩៨៥ ហិកតា**។

៤៦. យោងតាមលទ្ធផលចុះសិក្សាវាយតំលៃរបស់ក្រុមការងារខាងលើ (កំណត់ហេតុចុះថ្ងៃទី ២៩ ខែ កមរា ឆ្នាំ ២០០៩ ជូនភ្ជាប់ក្នុងឧបសម្ព័ន្ធ និងយោងតាមរបាយការណ៍ ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៩។ រាជរដ្ឋាភិបាលបានសំរេច ឯកភាពជាគោលការណ៍អនុញ្ញាតឱ្យក្រុមហ៊ុនធ្វើវិនិយោគដាំដំណាំពោត លើផ្ទៃដីសម្បទានសរុបចំនួន ***៩.៩៨៥ ហិកតា*** តាមលិខិតលេខ ៤០០ សជណ ចុះថ្ងៃទី ០៥ ខែ មិនា ឆ្នាំ ២០០៩ របស់ទីស្តីការគណៈរដ្ឋមន្រ្តី។ បន្ទាប់ពីទទួលបានគោលការណ៍ពីរាជរដ្ឋាភិបាល ក្រសួងបានចាត់ក្រុមការងារចុះកំណត់ចំណុចគោលព្រំដីសម្បទាន និងពិនិត្យកាត់ចេញ ផ្ទៃដីពាក់ពន្ធ័ជាមួយប្រជាពលរដ្ឋ និងតំបន់ការពារ

ផ្សេងៗ លទ្ធផលចុះសិក្សានេះបានទទួលដូចមានក្នុងរបាយការណ៍ ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៩ ជូនភ្ជាប់ក្នុងឧបសម្ព័ន្ធ២ ។

៤៧. យោងលិខិតលេខ ៤០០ សជណ ចុះថ្ងៃទី ០៥ ខែ មិនា ឆ្នាំ ២០០៩ របស់ ទីស្តីការគណៈរដ្ឋមន្ត្រី និងផ្នែកតាមឯកសារពាក់ពន្ធ័ខាងលើក្រុមហ៊ុនយើងខ្ញុំចុះហត្ថលេខាលើកិច្ចសន្យា ស្តីពីការវិនិយោគដំណាំកសិ-ឧស្សាហកម្ម( ពោត)ដំណាំផ្សេងៗ និងសាងសង់រោងចក្រកែច្នៃពោត ជាមួយក្រសួងបរិស្ថាន នាថ្ងៃទី ២៧ ខែ មិនា ឆ្នាំ ២០០៩( ឯកសារជូនភ្ជាប់នៅក្នុងឧបសម្ព័ន្ធ២) ។

៤៨. បច្ចុប្បន្នការបំពេញឯកសារតាមនិតិវិធីត្រូវបានបញ្ចប់ ដូច្នេះទាមទារអោយក្រុមហ៊ុន អនុវត្តតាមប្រការនៃកិច្ចសន្យានាថ្ងៃទី ២៧ ខែ មិនា ឆ្នាំ ២០០៩ រវាងក្រុមហ៊ុនជាមួយ ក្រសួងបរិស្ថាន ។ ចំពោះមុខក្រុមហ៊ុនត្រូវរៀបចំផែនការមេ លើផ្ទៃដីសំរាប់ធ្វើអាជីវកម្ម-ផលិតកម្ម សរុបចំនួន **៩.៩៨៥ ហិកតា** ។

### ៣-៥-៤-២ ការបែងចែកអនុតំបន់ក្នុងតំបន់ដីសម្បទាន

៤៩. យោងតាមផែនទីភ្ជាប់ក្នុងកិច្ចសន្យាបណ្តោះអាសន្ន ស្តីពីការវិនិយោគដាំដំណាំកសិ-ឧស្សាហកម្ម (ពោត) ដំណាំផ្សេងៗ និងសាងសង់រោងចក្រកែច្នៃពោត ជាមួយក្រសួងបរិស្ថាន នាថ្ងៃទី ២៧ ខែ មិនា ឆ្នាំ ២០០៩ និងតាមការគណនា តាមប្រព័ន្ធ GIS ឃើញថាលើផែនទីមានផ្ទៃដីសរុបសំនួន **៩.៩៨៥ ហិកតា** ។ ការរៀបចំផែនការមេនេះ គឺក្រុមហ៊ុនរៀបចំលើទំហំផ្ទៃដីសំរាប់ធ្វើអាជីវកម្ម-ផលិតកម្មចំនួន **៩.៩៨៥ ហិកតា** លើផ្ទៃដីសរុបចំនួន **៩.៩៨៥ ហិកតា** ផ្ទៃដីនេះ មានបញ្ជាក់ក្នុងតារាងខាងក្រោម ។

| | | |
|---|---|---|
| - ផ្ទៃដីដាំពោត | = | ៩.៤៨៥ ហិកតា |
| ផ្ទៃដីសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ | = | ៥០០ ហិកតា |
| សរុបផ្ទៃដីអាជីវកម្ម | = | ៩.៩៨៥ ហិកតា |

៥០. លើផ្ទៃដីនេះក្រុមហ៊ុនយើងខ្ញុំធ្វើការបែងចែកជា០៥ អនុតំបន់សំរាប់ធ្វើការដាំដុះតាមឆ្នាំនីមួយៗ ដូចមាន ផែនទីជូនភ្ជាប់ ក្នុងគំរោងផែនការមេ ។ ការបែងចែកទំហំផ្ទៃដីសំរាប់ដាំដុះ តាមអនុតំបន់នីមួយៗ មានដូចខាងក្រោមះ

៥១. **អនុតំបន់ទី I:** អនុតំបន់ទី I មានផ្ទៃដីសរុបចំនួន ២.០០០ ហិកតា ចំណុចនិយាមកាសំរាប់កំណត់អនុតំបន់ទី១មានបញ្ជាក់ក្នុងតារាងខាងក្រោមះ

**តារាង៣-១-i : តារាងបញ្ជាក់ពីចំណុចនិយាមកា នៃអនុតំបន់ទី I**

| ឈ្មោះចំណុច | ចំណុចនិយាមកា | |
|---|---|---|
| | X | Y |
| A | ៤០៤០១៤ | ១២៩៤២៤៤ |
| B | ៣៩៩០០៨ | ១២៩៥៧៣៣ |
| C | ៣៩៨៨៥៧ | ១២៩៨៩៩៦ |
| D | ៤០៤០២៣ | ១២៩៨៩៩៥ |

៥២. **អនុតំបន់ទី II:** អនុតំបន់ទី II មានផ្ទៃដីសំរាប់ធ្វើអាជីវកម្ម-ផលិតកម្ម មានចំនួន ២.០០០ ហិកតា។ ចំណុចនិយាមកាសំរាប់កំណត់ អនុតំបន់ទី២ មានបញ្ជាក់ក្នុងតារាងខាងក្រោម:

**តារាង៣-១-ii : តារាងបញ្ជាក់ពីចំណុចនិយាមកា នៃអនុតំបន់ទី II**

| ឈ្មោះចំណុច | ចំណុចនិយាមកា | |
|---|---|---|
| | X | Y |
| C | ៣៩៨៨៥៧ | ១២៩៨៩៩៧ |
| D | ៤០៤០២៤ | ១២៩៨៩៩៦ |
| E | ៤០៤០២១ | ១៣០៤៥០៥ |
| F | ៤០០០៦១ | ១៣០៤៥០៥ |

Draft

៥៣. **អនុតំបន់ទី III:** អនុតំបន់ទី III មានផ្ទៃដីសំរាប់ធ្វើអាជីវកម្ម-ផលិតកម្ម មានចំនួន ២.០០០ហិកតា ចំណុចនិយាមកាសំរាប់កំណត់អនុតំបន់ទី៣ មានបញ្ជាក់ក្នុងតារាងខាងក្រោម:

**តារាង៣-១-iii: តារាងបញ្ជាក់ពីចំណុចនិយាមកានៃអនុតំបន់ទី III**

| ឈ្មោះចំណុច | ចំណុចនិយាមកា | |
|---|---|---|
| | X | Y |
| E | ៤០៤០២១ | ១៣០៤៥០៥ |
| G | ៤០៤០២៧ | ១៣០៦០៩១ |
| H | ៤០២២២៨ | ១៣០៧៦១២ |
| I | ៤០២២៣៧ | ១៣១១៦៣២ |
| J | ៤០១៤១៣ | ១៣១១៦៤១ |

| | | |
|---|---|---|
| K | ៣៩៩៤៨៩ | ១៣១០១៨២ |
| M | ៣៩៩៤៩៧ | ១៣០៤៧៧៨ |
| F | ៤០០០៦១ | ១៣០៤៥០៥ |

**៩៤. អនុតំបន់ទី IV:** អនុតំបន់ទី IV មានផ្ទៃដីសំរាប់ធ្វើ អាជីវកម្ម-ផលិតកម្ម មានចំនួន ២.០០០ ហិកតា។ ចំណុចនិយាមកាសំរាប់កំណត់អនុតំបន់ទី៤ មានបញ្ជាក់ក្នុងតារាងខាងក្រោម:

**តារាង៣-១-iv:តារាងបញ្ជាក់ពីចំណុចនិយាមកា នៃអនុតំបន់ទី IV**

| ឈ្មោះចំណុច | ចំណុចនិយាមកា | |
|---|---|---|
| | X | Y |
| M | ៣៩៩៤៩៧ | ១៣០៤៧៧៨ |
| K | ៣៩៩៤៨៩ | ១៣១០១៨២ |
| L | ៣៩៦៦០២ | ១៣០៩៤៩៨ |
| O | ៣៩២៩៥៤ | ១៣០៩៤៩៨ |
| N | ៣៩២៩០៨ | ១៣០៥៩៥៤ |

**៩៥. អនុតំបន់ទី V:** អនុតំបន់ទី V មានផ្ទៃដីសំរាប់ធ្វើ អាជីវកម្ម-ផលិតកម្ម មានចំនួន ១.៩៨៥ ហិកតា។ ចំណុចនិយាមកាសំរាប់កំណត់អនុតំបន់ទី៥ មានបញ្ជាក់ក្នុងតារាងខាងក្រោម:

**តារាង៣-១-v:តារាងបញ្ជាក់ពីចំណុចនិយាមកា នៃអនុតំបន់ទី V**

| ឈ្មោះចំណុច | ចំណុចនិយាមកា | |
|---|---|---|
| | X | Y |
| O | ៣៩២៩៥៤ | ១៣០៩៤៩៨ |
| P | ៣៩៣១៧៣ | ១៣១៥៤១៣ |
| Q | ៣៩៤០៩៩ | ១៣១៦០០១ |
| R | ៣៩៥២៥១ | ១៣១៥៩៥៥ |
| S | ៣៩៦៥៨៤ | ១៣១២៤៥២ |
| L | ៣៩៦៦០២ | ១៣០៩៤៩៨ |

<u>បញ្ជាក់</u> :

- *ទំហំផ្ទៃដីដែលកំណត់តាមអនុតំបន់នីមួយៗ គឺជាទំហំផ្ទៃដីសំរាប់ធ្វើការដាំដុះ និង ធ្វើអាជីវកម្ម-ផលិតកម្ម (តារាងឧបសម្ព័ន្ធទី១ក ជូនភ្ជាប់) ក្រុមហ៊ុនគ្រោងផែនការដាំដុះដូចតទៅ:*

Draft

*ឆ្នាំទី១ ដាំក្នុងអនុតំបន់ ទី១ ឆ្នាំទី២ ដាំក្នុងអនុតំបន់ទី២ ដាំក្នុងអនុតំបន់ទី៣ អនុតំបន់ទី៤ និង អនុតំបន់ទី៥ ។*

*- ក្រុមហ៊ុនគ្រោងផ្ទៃដីចំនួន ៥០០ ហិកតា សំរាប់សំណង់ផ្សេងៗដូចជា ទីស្នាក់ការ លំនៅដ្ឋាន ឃ្លាំង ប្រព័ន្ធផ្លូវ ប្រព័ន្ធស្រោចស្រព.... ។ល។ ដោយឡែក ចំពោះរោងចក្រកែច្នៃ ក្រុមហ៊ុនយើងខ្ញុំ មានផែនការ សាងសង់រោងចក្រកែច្នៃ និងសំងួតពោត ក្នុងតំបន់ដីសម្បទាននេះ ។*

## ៣-៥-៤-៣ កម្មវិធីប្រើប្រាស់ដីតាមអនុតំបន់

**៥៦.** គំរោងប្រើប្រាស់ផ្ទៃដីក្នុងតំបន់ដីសម្បទាន ត្រូវធ្វើតាមអនុតំបន់នីមួយៗ ដោយគ្រោងអោយហើយក្នុងកំឡុងពេល២ ឆ្នាំ តាមកម្មវិធីការងារប្រើប្រាស់ដី ដូចខាងក្រោម:

**<u>តារាងប្រើប្រាស់ដីរបស់ក្រុមហ៊ុន (H L H Agriculture (CAMBODIA) CO., LTD)</u>**

| លេខអនុតំបន់ | ផ្ទៃដីសម្បទានសរុប | ផ្ទៃដីអាជីវកម្ម-ផលិតកម្ម |
|---|---|---|
| I | ២០០០ | ២០០០ |
| II | ២០០០ | ២០០០ |
| III | ២០០០ | ២០០០ |
| IV | ២០០០ | ២០០០ |
| V | ១៩៨៥ | ១៩៨៥ |
| **ផ្ទៃដីសរុប** | **៩៩៨៥** | **៩៩៨៥** |

Draft

**៥៧.** នៅក្នុងផ្ទៃដីសរុបដែលត្រូវដាំពោតចំនួន ៩.៩៨៥ ហិកតានេះ ក្រុមហ៊ុនយើងខ្ញុំបានគ្រោងធ្វើការដាំដុះ និងបែងចែកផ្ទៃដីដាំដុះតាមឆ្នាំនីមួយៗ ដូចខាងក្រោម :

<u>ដាំលើកទី១(ពីខែ មិនា ដល់ខែ កក្កដា ឆ្នាំ ២០០៩)</u> : ក្រុមហ៊ុនគ្រោងដាំដុះពោតចំនួន ២០០០ ហិកតា ក្នុងអនុតំបន់ទី-១។

<u>ដាំលើកទី២(ពីខែ សីហា ដល់ខែ ធ្នូ ឆ្នាំ ២០០៩)</u> : ក្រុមហ៊ុនគ្រោងដាំដុះពោតបន្ថែមចំនួន ២.០០០ ហិកតា ក្នុងអនុតំបន់ទី-២។

<u>ដាំលើកទី៣(ពីខែ មករា ដល់ខែ មេសា ឆ្នាំ ២០១០)</u> : ក្រុមហ៊ុនគ្រោងដាំដុះពោតបន្ថែមចំនួន ២.០០០ ហិកតា ក្នុងអនុតំបន់ទី-៣។

ដាំលើកទី៤ (ពីខែ ឧសភា ដល់ខែ សីហា ឆ្នាំ ២០១០) : ក្រុមហ៊ុនគ្រោងដាំដុះពោតបន្ថែមចំនួន ២.០០០ ហិកតា ក្នុងអនុតំបន់ទី-៤។

ដាំលើកទី៥ (ពីខែ កញ្ញា ដល់ខែ ធ្នូ ឆ្នាំ ២០១០) : ក្រុមហ៊ុនគ្រោងដាំដុះពោតបន្ថែមចំនួន ១.៩៨៥ ហិកតា ក្នុងអនុតំបន់ទី-៥។

តារាងបង្ហាញពីផែនការដាំដុះពោតរយៈពេល ០៥ ឆ្នាំ (២០០៩-២០១៣) ដូចខាងក្រោម :

**តារាង ៣-២ : ផែនការរៀបចំដីវិនិយោគដាំដំណាំពោត ពីឆ្នាំ ទី១ ដល់ឆ្នាំទី៥**

| មុខដំណាំ | ដាំលើកទី-១ | ដាំលើកទី-២ | ដាំលើកទី-៣ | ដាំលើកទី-៤ | ដាំលើកទី-៥ |
|---|---|---|---|---|---|
| ដំណាំពោត | ២.០០០ | ២.០០០ | ២.០០០ | ២.០០០ | ១.៩៨៥ |
| សរុបផ្ទៃដីដាំដុះ(ហ.ត) | ២.០០០ | ២.០០០ | ២.០០០ | ២.០០០ | ១.៩៨៥ |

*បញ្ជាក់ : ផ្ទៃដីដែលអាចដាំដុះបានមានចំនួន ៩.៩៨៥ ហិកតា ។*

## ៣-៥-៤-៤ បច្ចេកទេសដាំដុះពោត

### ៣-៥-៤-៤-១ ស្ថានភាពទូទៅ

**៩៨.** ពោតជាដំណាំមួយប្រភេទ ដែលប្រជាកសិករយើងស្គាល់ស្ទើរគ្រប់គ្នាទាំងអស់ ហើយដំណាំនេះក៏បានដាំដុះលើផ្ទៃដីធំគួរសម ស្ទើរពាសពេញនៃប្រទេសកម្ពុជាយើងដែរ។ ជាទូទៅប្រជាកសិករតែងនិយមយកពោតមកធ្វើជាបង្អែម និងចំណីសត្វជាដើម,...។ល។ សារៈសំខាន់នៃដំណាំនេះនៅប្រទេសកម្ពុជាយើង ក៏ដូចជាក្នុងពិភពលោក ក្រៅពីសារៈសំខាន់សំរាប់ធ្វើបង្អែម នៅប្រទេសមួយចំនួនគេបានកែច្នៃពោតសំរាប់បំពេញតំរូវការ ។ល។ ចំពោះប្រទេសកម្ពុជា នាពេលបច្ចុប្បន្ន ដំណាំពោតគឺមិនទាន់បានធ្វើការកែច្នៃជាលក្ខណៈទ្រង់ទ្រាយធំនៅនៅឡើយទេ លើលែងតែក្នុងសិប្បកម្មតូចៗ ប៉ុណ្ណោះដែលបានយកពោតធ្វើជានំជាដើម ក្រៅពីនេះគឺប្រជាកសិករយើង និយមយកពោតទៅស្ងោរហូប ឬធ្វើជាបង្អែមផ្សេងៗប៉ុណ្ណោះ។

### ៣-៥-៤-៤-២ តំបន់ដាំដុះ

**៩៩.** ជាទូទៅកសិករតែងតែនិយមដាំដុះនៅតំបន់តាមដងទន្លេ ក្រៅពីតំបន់ទន្លេ គេអាចដាំដំណាំនេះបានតាមតំបន់ដីខ្ពង់រាប ដីកោះ និងតាមជំរាលជើងភ្នំ លើដីក្រហម ឬដីខ្មៅជាដើម។

### ៣-៥-៤-៤-៣ បរិស្ថាននៃដំណាំពោត

៦០. ពោតជាដំណាំមួយប្រភេទ ដែលទាមទារកំដៅខ្លាំង ដើម្បីការលូតលាស់ដងដើម ក្នុងរយៈពេលលូតលាស់ដងដើម ស្លឹក ដំណាំនេះទាមទារសីតុណ្ហភាពខ្ពស់ជាមធ្យម ២០-២៥ អង្សាសេ លើកលែងតែដល់ដំណាក់កាលកកើតគ្រាប់ ។

៦១. ដំណាំនេះក៏ជាដំណាំមួយត្រូវការទឹកច្រើនបង្គួរដែរ ដូច្នេះដើម្បីធានាអោយបានផលល្អ គឺយើងត្រូវរៃយ៉ាងណាពេលដែលដំណាំស្ថិតក្នុងដំណាក់កាលលូតលាស់ខ្លាំង អាចចំពេលដែលមានភ្លៀងធ្លាក់ច្រើន ។

៦២. ប្រភេទដីដែលល្អសំរាប់ដំណាំពោត គឺដីល្បាប់ល្បាយខ្សាច់ មិនជាំទឹក ដីច្រោះទឹកល្អ ដីដែលមានជីជាតិល្អ ដែលមានស្រទាប់ទី១ជ្រៅ និងជាដីដែលមាន PH ៥.៥ ទៅ ៦.៨ ។ ចំពោះប្រទេសកម្ពុជាយើង ដីដែលសមស្របសំរាប់ដំណាំនេះ គឺដីខ្សាច់នៅតាមដងទន្លេ ដីក្រហម និងដីខ្មៅតាមតំបន់ខ្ពង់រាប ។ ដំណាំនេះដាំបានល្អនៅដីស្រទាប់ទី១ រាក់ (ជំរៅស្រទាប់ទី១ រាក់ជាង២០-៣០ស.ម) ចំពោះដីដែលមានក្រួសក្រហមច្រើននោះមិនសមស្របសំរាប់ដំណាំនេះឡើយ ។

### ៣-៥-៤-៤-៤ បច្ចេកទេសដាំដុះ និងថែរក្សា

#### ក. ការត្រៀមពូជ

៦៣. ពូជដែលក្រុមហ៊ុននាំយកមកដាំ មានប្រភពពី CP, Monsanto & LVN ពីប្រទេសវៀតណាម ជាប្រភេទគ្រាប់ពូជដែលមានលក្ខណៈធន់នឹងការបំផ្លាញពីសត្វល្អិត ។ ការទុកដាក់គ្រាប់ពូជមានសារសំខាន់ណាស់ដើម្បីធានាបាននូវអត្រាដំណុះ និងសុខភាពគ្រាប់ពូជ ។ ឃ្លាំងត្រូវមានខ្យល់ចេញចូលល្អ និងត្រូវមានការរៀបចំសំភារៈដើម្បីការពារការបំផ្លាញពីសត្វចង្រៃមួយចំនួនដូចជា កណ្តុរជាដើម ។ ជាការល្អគ្រាប់ពូជត្រូវដាំក្នុងរយៈពេល៦ខែមុនកាលបរិច្ឆេទអស់សុពលភាព ដើម្បីជៀសវាងគ្រាប់ពូជដុះមិនល្អ ។

#### ខ. ការរៀបចំដី

៦៤. ការភ្ជួររាស់ជាទូទៅចំពោះដំណាំពោត ក៏ប្រហាក់ប្រហែលនឹងដំណាំចំការផ្សេងៗទៀតដែរ ។ ការភ្ជួររាស់ក្នុងគោលបំណងធ្វើឡើងដើម្បីជ្រុំជ្រួយដីអោយផុសល្អ ដែលអាចបង្កអោយដំណាំដុះលូតលាស់ឆាប់ ម្យ៉ាងទៀតតាមរយៈការរៀបចំដី យើងអាចសំលាប់ស្មៅ សត្វល្អិត និងជំងឺមួយចំនួន ។ ចំនួននៃការភ្ជួររាស់អាស្រ័យទៅលើភាពទន់ និងរឹង របស់ដី ។

Draft

**គ. របៀបដាំដុះ**

**៦៥.** ដំណាំពោតជាប្រភេទដំណាំ ដែលមានលក្ខណៈងាយស្រួលក្នុងការដាំដុះ។ បន្ទាប់ពីការរៀបចំដីបានល្អ និងរៀបចំជាជួរហើយ យើងត្រូវដាំពោតដោយប្រើប្រាស់ម៉ាស៊ីនដាំដោយមានចន្លោះជួរ ០,២០ម៉ែត្រ និងចន្លោះរងពី ០,៧០-០,៨០ម៉ែត្រ។

**៣-៥-៤-៤-៥ ការដាក់ជី:**

**៦៦.** ដំណាំពោតជាដំណាំមួយប្រភេទ ដែលត្រូវការជីច្រើនគួរសម ក្នុងចំណោមដំណាំសំខាន់ៗ ដំណាំពោតចំពោះលក្ខខណ្ឌប្រទេសកម្ពុជាយើង កសិករដាំមួយឆ្នាំពីរម្តង និង ប្រមូលផលពីរម្តងនោះ គឺយើងអាចណែនាំអោយកសិករយើងដាក់ជី ១៥.១៥.១៥ និងជីអ៊ុយរ៉េ។ ការដាក់ជីលើដំណាំពោតទូទៅប្រើប្រាស់នៅចន្លោះពី ៥០០-៦០០ គីឡូក្រាមក្នុងមួយហិកតា។

**៣-៥-៤-៤-៦ ការថែទាំដំណាំ និងគ្រប់គ្រងសត្វល្អិត**

**៦៧.** សត្វល្អិត និងសត្វចង្រៃផ្សេងៗ តែងតែកើតមាននៅគ្រប់ដំណាក់កាលដំណាំលូតលាស់។ សត្វល្អិត និងសត្វចង្រៃ នឹងត្រូវប្រើទៅតាមនៃការបំផ្លាញ។ ដំណាក់កាលនៃការលូតលាស់នៃដំណាំពោត ដោយរាប់ចាប់ពីការបណ្តុះមក មានសត្វល្អិតបំផ្លាញច្រើនប្រភេទទៅតាមដំណាក់កាលនីមួយៗ។ វិធានការណ៍សំរាប់គ្រប់គ្រងកត្តាចង្រៃទាំងនេះមាន (១) ការថែទាំពូជដោយប្រើប្រាស់ថ្នាំគីមីមុនពេលដាំ (២) ការគ្រប់គ្រងជីគីមី : ការបាញ់ថ្នាំគីមី និង / ប្រើជីគ្រាប់ដែលមានសារធាតុសកម្មសំរាប់កំចាត់សត្វល្អិត (៣) ត្រួតពិនិត្យទ្បៀងទាត់ : គ្រាប់ពូជអាចមានសត្វល្អិតច្រើនប្រភេទ (៤) ការគ្រង់គ្រងវិទ្យាសាស្ត្រ :ការប្រើប្រាស់ប៉ារ៉ាស៊ីត។

**៣-៥-៤-៤-៧ ប្រព័ន្ធស្រោចស្រព**

**៦៨.** ពោតក៏ជាដំណាំដែលត្រូវការទឹកបង្ហូរ ជាពិសេសនៅពេលពោតស្ថិតក្នុងដំណាក់កាលលូតលាស់ដែលងាយនឹងជះឥទ្ធិពលដល់ការលូតលាស់របស់ដំណាំ ។

ក-វិធីសាស្ត្រស្រោចស្រពតាមបែបធម្មជាតិពេលមានភ្លៀងធ្លាក់

ខ-ការស្រោចស្រពដោយប្រើប្រព័ន្ធប្រឡាយ និងបំពង់ទំហំធំសំរាប់បង្ហូរទឹក

**៦៩.** បរិមាណទឹកស្រោចស្រពត្រូវបានណែនាំពី ៣៥០ ទៅ ៨០០ មីលីលីត្រ ក្នុងមួយហិកតា អាស្រ័យលើប្រភេទដី និង លក្ខខណ្ឌអាកាសធាតុ។ ការប្រើប្រាស់ប្រព័ន្ធបង្ហូរមានលក្ខណៈអំណោយផលនៅពេលមានភ្លៀង

Draft

ធ្លាក់ខ្លាំង ចំណែកការប្រើប្រាស់ប្រព័ន្ធស្រោចស្រពមានលក្ខណៈល្អនៅរដូវប្រាំងនៅ។ គ្រប់ដំណាក់កាលនៃការលូតលាស់របស់ដំណាំពោតក៏ត្រូវបានណែនាំដូចខាងក្រោម :

- ស្រោចស្រពលើកទី ១ : ពី ១០ ទៅ ១២ ថ្ងៃ ក្រោយពេលដាំ (តាមជំរើស)
- ស្រោចស្រពលើកទី ២ : ពី ២៥ ទៅ ៣០ ថ្ងៃ ក្រោយពេលដាំ
- ស្រោចស្រពលើកទី ៣ : ពី ៤៥ ទៅ ៥០ ថ្ងៃ ក្រោយពេលដាំ
- ស្រោចស្រពលើកទី ៤ : ពី ៦០ ទៅ ៦៥ ថ្ងៃ ក្រោយពេលដាំ
- ស្រោចស្រពលើកទី ៥ : ពី ៧៥ ទៅ ៨០ ថ្ងៃ ក្រោយពេលដាំ

### ៣-៥-៤-៥ ការប្រមូលផល

**៧០.** វាមានសារៈសំខាន់ណាស់ដែលត្រូវប្រមូលផលពោត នៅដំណាក់កាលដែលពោតចាប់ផ្តើមទុំពេញបន្ទុកឬពោតមានអាយុពី ៩០-១២០ថ្ងៃបន្ទាប់ពីថ្ងៃដាំ។ វានឹងធ្វើអោយយើងខាងបង់ទិន្នផល បើសិនជាយើងចាប់ផ្តើមប្រមូលផលពោតនៅពេលពោតស្ថិតក្នុងដំណាក់កាលដាក់ម្សៅ ឬមិនទាន់ទុំល្អនោះ។ នៅពេលប្រមូលផលយើងត្រូវហែកសំបកក្រៅដោយកាច់យកតែផ្លែ និងត្រូវសំងួតពោតបន្ថយសំនើមដើម្បីរក្សាទុកក្នុងឃ្លាំងមិនអោយខូច។ ចំពោះការដាំពោតទ្រង់ទ្រាយតូច ឬជាលក្ខណៈគ្រួសារការប្រមូលផលមិនសូវមានបញ្ហាអ្វីចោទទេ ។

### ៣-៥-៥ ការធ្វើផែនការវិនិយោគលើផលិតកម្ម និង អាជីវកម្ម

ការចំណាយថ្លៃដើមផលិតកម្មលើការដាំដុះដំបូង ក្នុងមួយហិកតា ត្រូវបានគ្រោងចំនួន ៩២២.៦០ ដុល្លាអាមេរិច សំរាប់ដំណាំពោត ដែលក្នុងនោះរួមបញ្ចូលចំណាយអថេរមួយចំនួន ដូចខាងក្រោម:

**តារាង ៣-៣ : គំរោងថវិកាចំណាយ**

| លរ | មុខចំណាយ | ពោត | ផ្សេងៗ |
|---|---|---|---|
| ១ | ឈូសឆាយ-រៀបចំដី land Clearance & Preparation | ៣០០.០០ | |
| ២ | ចំណាយពូជ ដី ថ្នាំ ឧបករណ៍ Seed, Fertilizer,Chemicals&Tool | ៤៣០.១០ | |
| ៣ | ចំណាយពលកម្ម Labor Costs | ១៦២.៥០ | |
| ៤ | ចំណាយស្រោចស្រព ដឹកជញ្ជូន និងផ្សេងៗ Irrigation Transport Cost | ៣០.០០ | |
| | ចំណាយសរុប Total Costs (US$) | **៩២២.៦០** | |

Draft

## ៧១. ផែនការចំណាយផលិតកម្មដាំដុះ និង កែច្នៃ

គំរោងការចំណាយនៃការអភិវឌ្ឍន៍ដាំដុះដំណាំកសិ-ឧស្សាហកម្មៈ ដំណាំពោត និងការកែច្នៃផលិតផលពោត ត្រូវបានបែងចែកជាបីប្រភេទគឺៈ

១- ចំណាយលើការដាំដុះដំបូង (Plantation Development Costs)

២- ចំណាយប្រតិបត្តិការ អាជីវកម្ម (Operating Costs)

៣- ចំណាយថេរ (Fixed Costs)

**៧២.** ចំណាយលើការដាំដុះដំបូង - ចំណាយប្រតិបត្តិការអាជីវកម្ម ត្រូវបានគិតជាចំណាយអថេរ (Variable Costs) ដែលក្នុងនោះមានៈ

- ចំណាយលើពលកម្ម ការដាំដុះ ការថែទាំជាប្រចាំ
- ចំណាយលើការប្រមូលផល ចំណាយលើការកែច្នៃផលិតផល
- ចំណាយលើការដឹកជញ្ជូន ចំណាយលើម៉ាខេតធីង និង
- ចំណាយប្រតិបត្តិការផ្សេងៗទៀត ។

**៧៣.** ចំណាយថេរ (Fixed Costs) គឺរួមមានបញ្ចូលលើការប្រាក់រំលោះរបស់អាគារ ឃ្លាំង ទព្វសំភារៈ ចំណាយលើការប្រាក់ ធានារ៉ាប់រងសង្គម និងចំណាយលើការបង់ពន្ធប៉ាតង់នានា ។

នៅឆ្នាំទី១ ថវិកាគ្រោងចំណាយសរុបមានចំនួន ៣.៤៣៥.៣៧៥ ដុល្លាអាមេរិក សំរាប់ការដាំដុះលើផ្ទៃដី ២០០០ ហិកតា ដែលក្នុងនោះការចំណាយលើការដាំដុះមានចំនួន ១.៧០៦.៨១០ ដុល្លាអាមេរិក ចំណាយប្រតិបត្តិការសរុបមានចំនួន ១.៥០៧.៩០០ ដុល្លាអាមេរិក ចំណាយថេរមានចំនួន ២២០.៦៦៥ ដុល្លាអាមេរិក ។ ចំណាយលំអិត មានបង្ហាញជូនឧបសម្ព័ន្ធ៥ក ( ក្នុងឧបសម្ព័ន្ធ៩) ។

នៅឆ្នាំទី២ ផ្ទៃដីដាំដុះពោតចំនួន ២០០០ហិកតា ដែលត្រូវការចំណាយថវិកាចំនួន ៣.៥៧៦.៦៧៧ ដុល្លាអាមេរិក ក្នុងនោះការចំណាយលើការដាំដុះមាន ចំនួន១.៧៥២.៩៤០ ដុល្លាអាមេរិក ចំណាយប្រតិបត្តិការមានចំនួន ១.៦៣៩.៦០០ ដុល្លាអាមេរិក និង ចំណាយថេរមានចំនួន ១៨៤.១៣៧ ដុល្លាអាមេរិក ។

នៅឆ្នាំទី៣ ផ្ទៃដីដាំដុះគ្រោងដាំពោតមានចំនួន ២០០០ ហិកតា ដែលការចំណាយសរុបមានចំនួន ៤.៥៦៣.៩៣៣ ដុល្លាអាមេរិក ក្នុងនោះការចំណាយលើការដាំដុះមានចំនួន ១.៧៥២.៩៤០ ដុល្លាអាមេរិក ចំណាយប្រតិបត្តិការមានចំនួន ២.៥១០.២០០ ដុល្លាអាមេរិក និងចំណាយថេរមានចំនួន ៣០០.៧៩៣ ដុល្លាអាមេរិក។

នៅឆ្នាំទី៤ ផ្ទៃដីដាំដុះពោតគ្រោងចំនួន ២០០០ ហិកតា ដែលការចំណាយមាន ៤.៦៧៨.៥៩៣ ដុល្លាអាមេរិក ក្នុងនោះការចំណាយលើការដាំដុះមានចំនួន ១.៧៥២.៩៤០ ដុល្លាអាមេរិក ចំណាយប្រតិបត្តិការមានចំនួន ២.៦០៨.២០០ ដុល្លាអាមេរិក និងចំណាយថេរមានចំនួន ៣១៧.៤៥៣ ដុល្លាអាមេរិក។

នៅឆ្នាំទី៥ ផ្ទៃដីដាំដុះពោតគ្រោងចំនួន ១.៩៨៥ ហិកតា ដែលការចំណាយមាន ៥.០២១.៧៨៧ ដុល្លាអាមេរិក ក្នុងនោះការចំណាយលើការដាំដុះមានចំនួន ១.៧៥២.៩៤០ ដុល្លាអាមេរិក ចំណាយប្រតិបត្តិការមានចំនួន ២.៦៨៦.៤០០ ដុល្លាអាមេរិក និងចំណាយថេរមានចំនួន ៥៨២.៤៤៧ ដុល្លាអាមេរិក។

**៧៤.** សមាមាត្រនៃការចំណាយនៅឆ្នាំទី១ លើការដាំដុះដំបូងមានចំនួន ៤៩ភាគរយ នៃចំណាយសរុប ៤៣ ភាគរយ លើចំណាយប្រតិបត្តិការ និង ០៨ភាគរយ លើចំណាយថេរ។

ការចំណាយលើការដាំដុះ និងការធ្វើអាជីវកម្ម ដំណាំកសិ-ឧស្សាហកម្មៈ ពោត រយៈពេល ៥ឆ្នាំដំបូង ត្រូវបានប៉ាន់ស្មាន និងរៀបរាប់លំអិតដូចខាងក្រោមនេះ។

Draft

ការចំណាយលើការដាំដុះដំបូង ដំណាំកសិ-ឧស្សាហកម្មៈ ពោត ពីឆ្នាំទី១ ដល់ឆ្នាំទី៥

| ល.រ | មុខចំណាយ | ឆ្នាំទី-១ ២០០៩ | ឆ្នាំទី-២ ២០១០ | ឆ្នាំទី-៣ ២០១១ | ឆ្នាំទី-៤ ២០១២ | ឆ្នាំទី-៥ ២០១៣ |
|---|---|---|---|---|---|---|
| ១ | សរុបចំណាយដាំដុះ | ១.៧០៦.៨១០ | ១.៧៥២.៩៤០ | ១.៧៥២.៩៤០ | ១.៧៥២.៩៤០ | ១.៧៥២.៩៤០ |
| ២ | សរុបចំណាយប្រតិបត្តិការ | ១.៥០៧.៩០០ | ១.៦៣៩.៦០០ | ២.៥១០.២០០ | ២.៦០៨.២០០ | ២.៦៨៦.៤០០ |
| ៣ | សរុបចំណាយអថេរ | ៣.២១៤.៧១០ | ៣.៣៩២.៩៤០ | ៤.២៦៣.១៤០ | ៤.៣៦១.១៤០ | ៤.៤៣៩.៣៤០ |
| ៤ | សរុបចំណាយថេរ | ២២០.៦៦៥.៦៧ | ១៨៤.១៣៧.៦៧ | ៣០០.៧៩៣.៦៧ | ៣១៧.៤៥៣.៦៧ | ៥៨២.៤៤៧.៦៩ |
| **សរុបចំណាយ (US$)** | | **៣.៤៣៥.៣៧៦** | **៣.៥៧៦.៦៧៨** | **៤.៥៦៣.៩៣៤** | **៤.៦៧៨.៥៩៤** | **៥.០២១.៧៨៨** |

៧៥. ក្នុងការទទួលជោគជ័យដ៏ធំធេងលើវិស័យសេដ្ឋកិច្ច-កសិកម្ម នៅក្នុងប្រទេសកម្ពុជា បានបម្រើជាភ្នាក់ងារកណ្តាល ដើម្បីបណ្តុះបណ្តាលកសិកករនៅក្នុងតំបន់ ជាមួយក្រុមហ៊ុនដូចជាចុះកិច្ចសន្យាស្តីអំពីជំនាញគ្រប់គ្រងដំណាំពោត ដាំដំណាំពោត និងលក់ពោតទៅឱ្យក្រុមហ៊ុនដើម្បីធ្វើការកែច្នៃពោត កិនពោតដើម្បីធ្វើជាអាហារសត្វ ដើម្បីកង្កើនជីវភាពរស់នៅឱ្យកាន់តែប្រសើរឡើង ។

៧៦. សំរាប់រោងចក្រសំងួតពោត ក្រុមហ៊ុនក៏មានគំរោងប្រមូលទិញពោតមិនទាន់កែច្នៃពីប្រជាកសិករនៅក្នុង តំបន់ដើម្បីយកមកសំងួត បន្ទាប់មកក្រុមហ៊ុន នឹងធ្វើការលក់នៅក្នុងប្រទេសកម្ពុជា ឬក៏នាំចេញទៅក្រៅប្រទេសទៅតាមច្បាប់ដែលមាននៅក្នុងប្រទេសកម្ពុជា ។

## ៣-៥-៦ ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ

### ៣-៥-៦-១ ប្រព័ន្ធផ្លូវ

៧៧. គំរោងផែនការសំរាប់ការរៀបចំប្រព័ន្ធផ្លូវ ក្នុងតំបន់ព្រៃសម្បទាន ក្រុមហ៊ុនមានផែនការសាងសង់ប្រព័ន្ធផ្លូវ ដោយមិនគិតពីផ្លូវចាស់ ។ ក្នុងករណីចាំបាច់ ឬមានកិច្ចសហការពីប្រជាពលរដ្ឋ អាជ្ញាធរមូលដ្ឋាន ក្រុមហ៊ុនយើងខ្ញុំ នឹងសាងសង់ ជួសជុលផ្លូវចាស់ដែលមានស្រាប់ ដើម្បីប្រើប្រាស់រួមជាសាធារណៈ ។

៧៨. ដើម្បីអោយការធ្វើអាជីវកម្ម-ផលិតកម្ម នៅក្នុងតំបន់ដីសម្បទាន ដំណើរការទទួលបានជ័យ ក្រុមហ៊ុនមានផែនការសាងសង់ប្រព័ន្ធផ្លូង ៥ប្រភេទ សំរាប់ជាខ្សែខ័ណ្ឌព្រំប្រទល់ជុំវិញតំបន់ដីសម្បទាន ជាព្រំប្រទល់សំរាប់ការបែងចែកអនុតំបន់ដីសម្បទាន និងបែងចែកជាឡូតិ៍សំរាប់ការដាំដុះ និងការគ្រប់គ្រង ។

៧៩. ផ្លូវទាំង ៥ប្រភេទនេះ មានបញ្ជាក់សង្ខេបក្នុងតារាងខាងក្រោម បន្ទាប់ពីការអត្ថាធិប្បាយពីផ្លូវនិមួយៗ ។ ប្រភេទផ្លូវនិមួយៗមានទំហំ ប្រវែងខុសៗគ្នា និងមានអត្ថប្រយោជន៍សំរាប់បំរើឱ្យការធ្វើអាជីវកម្ម-ផលិតកម្ម ផ្សេងៗពីគ្នាតាមប្រភេទផ្លូវ ។ តាមការសិក្សារបស់ក្រុមហ៊ុន និងការរៀបចំគំនូសប្លង់(ផែនទីទី២ ឧបសម្ព័ន្ធ១)សំរាប់ការសាងសង់ប្រពន្ធ័ផ្លូវទាំងនោះ ដូចខាងក្រោម :

៨០. **ផ្លូវមេព័ទ្ធជុំវិញតំបន់ដីសម្បទាន :** គឺជាផ្លូវដែលត្រូវសាងសង់ព័ទ្ធជុំវិញតំបន់ដីសម្បទាន ដែលមានចំងាយសរុប៧៧ គីឡូម៉ែត្រ និងទទឹងផ្លូវមានប្រវែង ១២ ម៉ែត្រ សរុបផ្ទៃដីសំរាប់កសាងផ្លូវមេព័ទ្ធតំបន់ដីសម្បទានមានចំនួន ៩២.៤ ហិកតា ។

៨១. ផ្លូវនេះធ្វើការសាងសង់តាមព្រំប្រទល់ ដីសម្បទានឆ្លងកាត់ចំណុច A, B, C, D, E, F, G, H, I, J, K, L, M, N, O, P, Q, R, S ។ ចំណុចនិយាមកាតាមចំណុចនិមួយៗខាងលើមានភ្ជាប់ក្នុងតារាងខាងក្រោមនេះ ។

Draft

| ចំណុចគោលព្រំប្រទល់ | អាប់ស៊ីស | អរដោណេ |
|---|---|---|
| A | ៤០៤០១៤ | ១២៩៤២៤៤ |
| B | ៣៩៩០០៨ | ១២៩៥៧៣៣ |
| C | ៣៩៨៨៥៧ | ១២៩៨៩៩៧ |
| D | ៤០៤០២៤ | ១២៩៨៩៩៦ |
| E | ៤០៤០២១ | ១៣០៤៥០៥ |
| F | ៤០០០៦១ | ១៣០៤៥០៥ |
| G | ៤០៤០២៧ | ១៣០៦០៩១ |
| H | ៤០២២២៨ | ១៣០៧៦១២ |
| I | ៤០២២៣៧ | ១៣១១៦៣២ |
| J | ៤០១៤១៣ | ១៣១១៦៤១ |
| K | ៣៩៩៤៨៩ | ១៣១០១៨២ |
| L | ៣៩៦៦០២ | ១៣០៩៤៩៨ |
| M | ៣៩៩៤៩៧ | ១៣០៤៧៧៨ |
| N | ៣៩២៩០៨ | ១៣០៥៩៩៤ |
| O | ៣៩២៩៥៤ | ១៣០៩៤៩៨ |
| P | ៣៩៣១៧៣ | ១៣១៥៤១៣ |
| Q | ៣៩៤០៩៩ | ១៣១៦០០១ |
| R | ៣៩៥២៥១ | ១៣១៥៩៩៥ |
| S | ៣៩៦៥៨៤ | ១៣១២៤៥២ |

៨២. សារប្រយោជន៍របស់ផ្លូវនេះ គឺដើម្បីជារបងកំណត់ព្រំប្រទល់ដីសម្បទាន ជាផ្លូវសំរាប់ធ្វើចរាចក្នុងការធ្វើអាជីវកម្ម-ផលិតកម្ម ការដឹកជញ្ជូន ជាផ្លូវយុទ្ធសាស្រ្តសំរាប់ការពារសន្តិសុខ និងសុវត្ថិភាពដូចជា: ការពារភ្លើងឆេះព្រៃ និងចល័តកំលាំងសន្តិសុខនៅពេលមានបញ្ហា.... ។ល ។

៨៣. **ប្រភេទផ្លូវមេក្នុងតំបន់ដីសម្បទាន:** គំរោងផែនការក្នុងការរៀបចំកសាងផ្លូវមេ ក្នុងតំបន់ដីសម្បទានគឺមានចំនួន ០៣ ខ្សែ ។ ខ្សែទី១ សាងសង់ពីទិសខាងត្បូងទៅទិសខាងជើង ចាប់ផ្តើមពីចំនុច T ដល់ចំណុច U ។ ខ្សែទី២ សាងសង់ពីទិសខាងកើតទៅទិសខាងលិច ចាប់ផ្តើមពីចំណុច U ដល់ចំណុច V ។ ខ្សែទី៣សាងសង់ពីទិសខាងត្បូងទៅទិសខាងជើង ចាប់ផ្តើមពីចំណុច V ដល់ចំណុច W ។ ផ្លូវទាំង ០៣ ខ្សែ មានប្រវែងសាងសង់

ប៉ាន់ស្មានសរុបចំនួន ២៩ គីឡូម៉ែត្រ និងមានទទឹង ១២ ម៉ែត្រ សរុបផ្ទៃដីសំរាប់កសាងផ្លូវមេក្នុងតំបន់ ដីសម្បទានមានចំនួន ៣៩.៨ហិកតា (ដូចមានផែនទី១-២)។ សារៈប្រយោជន៏របស់ផ្លូវមេក្នុងតំបន់ ដីសម្បទានគឺ :

- ជាផ្លូវសំរាប់ធ្វើចរាចរគ្រឿងចក្រដឹកនាំផលដែលទទួលបានពីការដាំដុះ និងផលិតផលផ្សេងៗ សំរាប់បំរើអោយការធ្វើអាជីវកម្ម-ផលិតកម្ម។
- ជាផ្លូវយុទ្ធសាស្រ្តសំរាប់ការពារសន្តិសុខ និងសុវត្ថិភាពដូចជា ការពារភ្លើងឆេះព្រៃ និងចល័តកំលាំងនៅពេលមានឧប្បទ្ទពហេតុកើតមានឡើង ក្នុងតំបន់ដីសម្បទាន.... ។ល។
- ចរាចរត្រួតពិនិត្យក្នុងតំបន់ដីសម្បទាន។

៨៤. **ប្រភេទផ្លូវមេចែកអនុតំបន់:** ផ្លូវមេចែកអនុតំបន់គឺជាប្រភេទផ្លូវកសាងឡើង ដើម្បីចែកអនុតំបន់ទាំង០៤ សំរាប់ធ្វើការដាំដុះតាមឆ្នាំនីមួយៗ និងសំរាប់បំរើអោយការធ្វើអាជីវកម្ម-ផលិតកម្ម។ ផ្លូវទាំងនេះក្រុមហ៊ុនមានផែនការកសាងប្រវែងប៉ាន់ស្មានសរុបចំនួន ១៨ គីឡូម៉ែត្រ និងទទឹងផ្លូវ១២ម៉ែត្រ ផ្ទៃដីប៉ាន់ស្មានសំរាប់ការសាងសង់សរុបមានចំនួន ២១.៦ ហិកតា។ ផ្លូវទាំង០៤ ខ្សែ នេះក្រុមហ៊ុនមានផែនការ កសាងដូចតទៅ:

- **ផ្លូវខ្សែទី ១** ផ្លូវនេះមានគំរោងសាងសង់ ចាប់ផ្តើមពីចំណុច C រត់ទៅទិសខាងកើតត្រង់ដល់ចំណុច **D** ដែលជាចំណុចបញ្ចប់របស់ផ្លូវនេះ។
- **ផ្លូវខ្សែទី ២** ផ្លូវនេះមានគំរោងសាងសង់ ចាប់ផ្តើមពីចំណុច E រត់ទៅទិសខាងលិចត្រង់ដល់ចំណុច **F** ដែលជាចំណុចបញ្ចប់របស់ផ្លូវនេះ។
- **ផ្លូវខ្សែទី ៣** ផ្លូវនេះមានគំរោងសាងសង់ ចាប់ផ្តើមពីចំណុច M រត់ទៅទិសខាងជើងត្រង់ដល់ចំណុច **K** ដែលជាចំណុចបញ្ចប់របស់ផ្លូវនេះ។

ចំណុចនិយាមកាតាមចំណុចនីមួយៗ មានបញ្ជាក់ក្នុងតារាង ភ្ជាប់ក្នុងឧបសម្ព័ន្ធ ១-២។

**៨៥. សារៈប្រយោជន៏របស់ផ្លូវមេក្នុងអនុតំបន់ដីសម្បទានគឺ :**

- ជាផ្លូវសំរាប់កំណត់ព្រំប្រទល់ឡូតិ៍ក្នុងអនុតំបន់នីមួយៗ។
- ជាផ្លូវសំរាប់អ្នកបច្ចេកទេសងាយស្រួលក្នុងការត្រួតពិនិត្យ និងគ្រប់គ្រង។
- ជាផ្លូវសំរាប់កម្មករប្រមូលផលតាមឡូតិ៍នីមួយៗ។
- ជាផ្លូវសំរាប់ធ្វើចរាចរគ្រឿងចក្រ ដឹកនាំផលដែលទទួលបានពីការដាំដុះ និងផលិតផលផ្សេងៗ សំរាប់បំរើអោយការធ្វើអាជីវកម្ម-ផលិតកម្ម។

Draft

- ជាផ្លូវយុទ្ធសាស្ត្រសំរាប់ការពារសន្តិសុខ និងសុវត្ថិភាពដូចជា ការពារភ្លើងឆេះព្រៃ និងចល័តកំលាំងនៅពេលមានឧប្បទ្ទហេតុកើតមានឡើង ក្នុងតំបន់ដីសម្បទាន... ។ល ។
- ចរាចរត្រួតពិនិត្យក្នុងតំបន់ដីសម្បទាន និងការពារការហូរច្រោះដី... ។ល ។

៨៦. **ប្រភេទផ្លូវមេក្នុងអនុតំបន់:** ផ្លូវមេក្នុងអនុតំបន់ដីសម្បទានគ្រោងធ្វើការកសាងសង់មានចំនួន ៣៣ ខ្សែ ប្រវែងផ្លូវប៉ាន់ស្មានសំរាប់ការសាងសង់នេះប្រមាណ ១៩០ គីឡូម៉ែត្រ និងមានប្រវែងទទឹងផ្លូវ ១០ ម៉ែត្រ ផ្ទៃដីប៉ាន់ស្មានសរុបចំនួន ១៩០ ដែលក្នុងនោះសាងសង់ពីទិសខាងជើងទៅទិសខាងត្បូងចំនួន ១១ ខ្សែ ស្មើនឹង ៩២ គីឡូម៉ែត្រ ផ្ទៃដីប៉ាន់ស្មាន សំរាប់សាងសង់ចំនួន ៩២ ហិកតា និងពីទិសខាងលិចទៅទិសខាងកើត ចំនួន ២២ ខ្សែ ស្មើនឹង ៩៨ គីឡូម៉ែត្រ ផ្ទៃដីប៉ាន់ស្មានសំរាប់សាងសង់ចំនួន ៩៨ ហិកតា។ ផ្លូវមេក្នុងតំបន់ដីសម្បទានមានគំលាតពីផ្លូវមួយចំងាយ ១គីឡូម៉ែត្រ (ផែនទីឧបសម្ព័ន្ធ១-២) ។

៨៧. **សារៈប្រយោជន៍របស់ផ្លូវមេក្នុងអនុតំបន់ដីសម្បទានគឺ :**

- ជាផ្លូវសំរាប់កំណត់ព្រំប្រទល់ឡូត៍ក្នុងអនុតំបន់នីមួយៗ។
- ជាផ្លូវសំរាប់អ្នកបច្ចេកទេសងាយស្រួលក្នុងការត្រួតពិនិត្យ និងគ្រប់គ្រង ។
- ជាផ្លូវសំរាប់កម្មករប្រមូលផលតាមឡូត៍នីមួយៗ។
- ជាផ្លូវសំរាប់ធ្វើចរាចគ្រឿងចក្រ ការដឹកនាំផលដែលទទួលបានពីការដាំដុះ និងផលិតផលផ្សេងៗ សំរាប់បំរើអោយការធ្វើអាជីវកម្ម-ផលិតកម្ម ។
- ជាផ្លូវយុទ្ធសាស្ត្រសំរាប់ការពារសន្តិសុខ និងសុវត្ថិភាពដូចជា ការពារភ្លើងឆេះព្រៃ និងចល័តកំលាំងនៅពេលមានឧប្បទ្ទហេតុកើតមានឡើងក្នុងតំបន់ដីសម្បទាន... ។ល ។
- ចរាចរត្រួតពិនិត្យក្នុងតំបន់ដីសម្បទាន និងការពារការហូរច្រោះដី... ។ល ។

៨៨. **ផ្លូវឡូត៍:** ផ្លូវឡូត៍គ្រោងធ្វើការសាងសង់សរុបចំនួន ៣០ ខ្សែ មានផ្លូវប្រវែង ១៧៦ ម៉ែត្រ ផ្ទៃដីប៉ាន់ស្មាន សំរាប់សាងសង់មានចំនួន ១៤០.៨ ហិកតា និងមានទទឹង ០៨ម៉ែត្រ។ ផ្លូវនេះសាងសង់ពីលិចទៅកើតចំនួន ២០ខ្សែ មានប្រវែង ៩៤ គីឡូម៉ែត្រ ផ្ទៃដីប៉ាន់ស្មានសំរាប់សាងសង់ចំនួន ៧៥.២ ហិកតា និងសាងសង់ពីជើងទៅត្បូងចំនួន ១០ ខ្សែ មានប្រវែង ៨២ គីឡូម៉ែត្រ ផ្ទៃដីប៉ាន់ស្មានសំរាប់សាងសង់ចំនួន ៦៥.៦ ហិកតា។ ផ្លូវឡូត៍គ្រោងធ្វើការសាងសង់គំលាតពីផ្លូវមួយចំងាយ ៥០០ ម៉ែត្រ ឬ គំលាត ៥០០ ម៉ែត្រ ពីផ្លូវផ្សេងៗទៀត (ផែនទីឧបសម្ព័ន្ធ១-២) ។

## ៨៩. សារៈប្រយោជន៍របស់ផ្លូវឡូតិ៍ក្នុងតំបន់ ដីសម្បទានគឺ :

- ជាផ្លូវសំរាប់កំណត់ព្រំប្រទល់ឡូតិ៍ក្នុងអនុតំបន់នីមួយៗ ។
- ជាផ្លូវសំរាប់អ្នកបច្ចេកទេសងាយស្រួលក្នុងការត្រួតពិនិត្យ និងគ្រប់គ្រង ។
- ជាផ្លូវសំរាប់កម្មករប្រមូលផលតាមឡូតិ៍នីមួយៗ ។
- ជាផ្លូវសំរាប់ធ្វើចរាចរគ្រឿងចក្រ ដឹកនាំផលដែលទទួលបានពីការដាំដុះ និងផលិតផលផ្សេងៗ សំរាប់បំរើអោយការធ្វើអាជីវកម្ម-ផលិតកម្ម ។
- ជាផ្លូវយុទ្ធសាស្ត្រសំរាប់ការពារសន្តិសុខ និងសុវត្ថិភាព ដូចជា ការពារភ្លើងឆេះព្រៃ និងចល័តកំលាំងនៅពេលមានឧប្បទ្ទវហេតុកើតមានឡើង ក្នុងតំបន់ដីសម្បទាន... ។ល ។
- ជាផ្លូវសំរាប់អោយកម្មករងាយស្រួលក្នុងការជញ្ជូនផលិតផល ដោយកំលាំងពលកម្ម ការថែទាំការពារភ្លើង និងសំរាប់ប្រមូលផ្តុំផល រួចដឹកចេញមកកន្លែងប្រមូលផ្តុំផលតាមឡូតិ៍ និងបន្តមកកាន់ រោងចក្រ ។
- ចរាចរត្រួតពិនិត្យក្នុងតំបន់ដីសម្បទាន និងការពារការហូរច្រោះដី... ។ល ។

*__បញ្ជាក់:__ -គំរោងការសាងសង់ផ្លូវទាំង ០៥ប្រភេទខាងលើនៅពេលអនុវត្ត ក្រុមហ៊ុនយើងខ្ញុំនឹងដំណើរការតាមទៅតាមសណ្ឋានដីជាក់ស្តែង ។ គំរោងផែនការសំរាប់ការរៀបចំប្រព័ន្ធផ្លូវ ក្នុងតំបន់ដីសម្បទាន ក្រុមហ៊ុនមានផែនការសាងសង់ប្រព័ន្ធផ្លូវដោយមិនគិតពីផ្លូវចាស់ ។*

*-ចំពោះផ្លូវសចាស់ដែលមានស្រាប់ក្នុងករណីចាំបាច់ និងមានកិច្ចសហការល្អពីប្រជាពលរដ្ឋ អាជ្ញាធរមូលដ្ឋាន ក្រុមហ៊ុនយើងខ្ញុំនឹងធ្វើការសាងសង់ ឬជួសជុលផ្លូវចាស់ ដែលមានស្រាប់នោះ សំរាប់ប្រើប្រាស់រួមជាសាធារណៈ ។*

**តារាង ៣-៤ : តារាងសង្ខេបពីប្រព័ន្ធផ្លូវសំរាប់ដំណើរការអភិវឌ្ឍន៍ក្នុងតំបន់ដីសម្បទាន**

| លរ | ប្រភេទផ្លូវ | ចំនួនខ្សែ | ប្រវែង គ.ម | ទទឹងផ្លូវ ម៉ែត្រ | ផ្ទៃដី ហ.ត |
|---|---|---|---|---|---|
| ១ | ផ្លូវមេព័ទ្ធជុំវិញដីសម្បទាន | ១ | ៧៧ | ១២ | ៩២.៤ |
| ២ | ផ្លូវមេនៅក្នុងដីសម្បទាន | ៣ | ២៩ | ១២ | ៣៤.៨ |
| ៣ | ផ្លូវមេបែងចែកអនុតំបន់ដីសម្បទាន | ៤ | ១៨ | ១២ | ២១.៦ |
| ៤ | ផ្លូវមេក្នុងអនុតំបន់ដីសម្បទានពីលិចទៅកើត | ២២ | ៩៨ | ១០ | ៩៨ |
| | ផ្លូវមេក្នុងអនុតំបន់ដីសម្បទានពីជើងទៅត្បូង | ១១ | ៩២ | ១០ | ៩២ |
| ៥ | ផ្លូវបែងចែកឡូតិ៍ពីលិចទៅកើត | ២០ | ៩៤ | ៨ | ៧៥.២ |
| | ផ្លូវបែងចែកឡូតិ៍ពីជើងទៅត្បូង | ១០ | ៨២ | ៨ | ៦៥.៦ |

| | | | | |
|---|---|---|---|---|
| សរុប | ៧១ | ៤៩០ | ៧២ | ៤៧៩.៦ |

### ៣-៥-៦-២ ប្រព័ន្ធស្រោចស្រព

៩០. ប្រភពទឹកសំរាប់បំរើអោយការស្រោចស្រពក្នុងតំបន់ដីសម្បទាន ពុំសូវមានលក្ខណៈអំណោយផលល្អ ព្រោះក្នុងតំបន់ដីសម្បទាន ពុំមានប្រភពទឹកធំៗហូរកាត់តែស្ទឹងត្រាំងក្រាំង និងស្ទឹងតាសាល ដែលហូរកាត់កណ្តាលតំបន់ដីសម្បទាន ដែលអាចជាប្រភពទឹកធម្មជាតិសំរាប់បំរើអោយការស្រោចស្រពក្នុងតំបន់សម្បទានបាន។

៩១. វិធីសាស្រ្តទាញទឹកយកមកប្រើប្រាស់គឺ ក្រុមហ៊ុនមានផែនការស្ថាបនាប្រព័ន្ធប្រឡាយ កសាងប្រឡាយបណ្តែត និងប្រើប្រាស់ទុយោ សំរាប់ការស្រោចស្រព ទៅតាមស្ថានភាពដីជាក់ស្តែងក្នុងតំបន់ដីសម្បទាន។ ម្យ៉ាងវិញទៀតក្នុងករណីជួបការលំបាក លើការទាញទឹកពីប្រភពទឹកដែលបានរៀបរាប់ខាងលើ ក្រុមហ៊ុនក៏មានផែនការ កសាងប្រព័ន្ធធារាសាស្រ្តស្ទាក់ទឹកភ្លៀង និងប្រើប្រាស់ប្រព័ន្ធទឹកក្រោមផងដែរ។

### ៣-៥-៦-៣ រោងចក្រកែច្នៃ និងសំងួតពោត

៩២. ក្រុមហ៊ុនមានគំរោងសាងសង់រោងចក្រកែច្នៃ សំងួតពោត និងហេដ្ឋារចនាសម្ព័ន្ធរបស់ក្រុមហ៊ុនចំនួន ០៥ កន្លែង ដោយគ្រោងលើផ្ទៃដីប្រហែល ២៥ ហិកតា សំរាប់ការសាងសង់។ ការសាងសង់រោងចក្រកែច្នៃ និងសំងួតពោត និងហេដ្ឋារចនាសម្ព័ន្ធរបស់ក្រុមហ៊ុន នឹងត្រូវចាប់ផ្តើមនៅឆ្នាំទី-១ និងត្រូវបំពាក់គ្រឿងចក្រកែច្នៃ និងឧបករណ៍សាងសង់ទំនើប។ រោងចក្រកែច្នៃ និងសំងួតពោតមានទីតាំងស្ថិតនៅក្នុងអនុតំបន់ **I, II, III, IV, V**។

### ៣-៥-៦-៤ ទីតាំង ទំហំផ្ទៃដីសំរាប់ហេដ្ឋារចនាសម្ព័ន្ធ

៩៣. ក្រុមហ៊ុនយើងខ្ញុំមានផែនការសាងសង់សំណង់មួយចំនួន សំរាប់ដំណើរក្នុងការធ្វើអាជីវកម្ម-ផលិតកម្មក្នុងតំបន់ដីសម្បទាន សំណង់ទាំងនោះមានដូចតទៅ :

- ផ្លូវមេព័ទ្ធជុំវិញតំបន់ដីសម្បទានគឺជាផ្លូវដែលត្រូវសាងសង់ព័ទ្ធជុំវិញតំបន់ដីសម្បទាន ដែលមានប្រវែងសរុប ៧៧ គីឡូម៉ែត្រ និងទទឹងផ្លូវមានប្រវែង ១២ ម៉ែត្រ សរុបផ្ទៃដីសំរាប់កសាងផ្លូវមេព័ទ្ធតំបន់ដីសម្បទាន មានចំនួន ៩២.៤ ហិកតា។
- ផ្លូវមេក្នុងតំបន់ដីសម្បទាន គឺមានចំនួន ០៣ ខ្សែ មានប្រវែងប៉ាន់ស្មានសរុបចំនួន ២៩ គីឡូម៉ែត្រ និងមានទទឹង ១២ ម៉ែត្រ សរុបផ្ទៃដីសំរាប់កសាង ផ្លូវមេក្នុង តំបន់ដីសម្បទានមានចំនួន ៣៤.៨ ហិកតា។

Draft

- ផ្លូវមេចែកអនុតំបន់កសាងចំនួន ០៥ ខ្សែ ប្រវែងប៉ាន់ស្មានសរុបចំនួន ១៨ គីឡូម៉ែត្រ និង ទទឹងផ្លូវ ១២ម៉ែត្រ ផ្ទៃដីប៉ាន់ស្មានសំរាប់ការសាងសង់សរុបមានចំនួន ២១.៦ ហិកតា។
- ផ្លូវមេក្នុងអនុតំបន់ដីសម្បទានមានចំនួន ៣៣ ខ្សែ ប្រវែងផ្លូវប៉ាន់ស្មានសំរាប់ការសាង សង់នេះប្រមាណ ១៩០ គីឡូម៉ែត្រ និងមានទទឹងផ្លូវប្រវែង ១០ម៉ែត្រ ផ្ទៃដីប៉ាន់ស្មានសរុបចំនួន ១៩០ ហិកតា ដែលក្នុងនោះសាងសង់ពីទិសខាងជើងទៅទិសខាងត្បូងចំនួន ១១ ខ្សែ ស្មើនឹង ៩២ គីឡូម៉ែត្រ ផ្ទៃដីប៉ាន់ស្មានសំរាប់សាងសង់ចំនួន ៩២ ហិកតា និង ពីទិសខាងលិចទៅទិសខាងកើតចំនួន ២២ ខ្សែ ស្មើនឹង ៩៨ គីឡូម៉ែត្រ ផ្ទៃដីប៉ាន់ស្មានសំរាប់សាងសង់ ចំនួន ៩៨ ហិកតា។
- ផ្លូវឡូត៍ក្នុងអនុតំបន់ដីសម្បទានគឺមានចំនួន ៣០ ខ្សែ មានប្រវែង ១៧៦ គីឡូម៉ែត្រ ផ្ទៃដីប៉ាន់ស្មានសំរាប់សាងសង់មានចំនួន ១៤០.៨ ហិកតា និងមានទទឹង ០៨ ម៉ែត្រ។ ផ្លូវនេះ ត្រូវសាងសង់ពីទិសខាងលិចទៅទិសខាងកើតចំនួន ២០ ខ្សែ មានប្រវែង ៩៤ គីឡូម៉ែត្រ ផ្ទៃដីប៉ាន់ស្មានសំរាប់សាងសង់ចំនួន ៧០.២ ហិកតា និងសាងសង់ពីជើងទៅត្បូងចំនួន ១០ ខ្សែ មានប្រវែង ៨២ គីឡូម៉ែត្រ ផ្ទៃដីប៉ាន់ស្មាន សំរាប់សាងសង់ចំនួន ៦៥.៦ ហិកតា។

៩៤. **សរុបផ្ទៃដីប៉ាន់ស្មានសំរាប់ប្រព័ន្ធផ្លូវទាំង ០៥ប្រភេទខាងលើមានចំនួន ៤៣១.២ ហិកតា។**

- ទីស្នាក់ការ ធំ និងផ្ទះស្នាក់នៅរបស់ថ្នាក់ដឹកនាំក្រុមហ៊ុនមានចំនួន ១០ កន្លែង ស្ថិតនៅក្នុងអនុតំបន់ទ I, II, III, IV, V។
- រោងចក្រកែច្នៃ និងសំងួតពោតចំនួន ១០ កន្លែង ស្ថិតនៅក្នុងអនុតំបន់ទី I, II, III, IV, V។
- ទីស្នាក់ការរង និងជំរុំកម្មករមានទាំង ០៥ កន្លែង ស្ថិតក្នុងអនុតំបន់ទី I, II, III, IV, V។
- ប៉ុស្តិយាមចំនួន ០២ ស្ថិតនៅអនុតំបន់ទី I, V។
- ប៉មយាមភ្លើងឆេះព្រៃ និង សន្តិសុខចំនួន ២៧ ស្ថិតនៅរាយក្នុងរាយក្នុងតំបន់ដីសម្បទាន ដូចមានក្នុងផែនទីជូនភ្ជាប់ (ផែនទីឧបសម្ព័ន្ធ១-២)។

**តារាង ៣-៥ : តារាងបញ្ជាក់ពីចំនួន ប្រភេទ ផ្ទៃដីសំណង់**

| ល.រ | ប្រភេទសំណង់ | ចំនួនសរុប | ឆ្នាំសាងសង់ | ផ្ទៃដី (ហ.ត) | កំណត់សំគាល់ |
|---|---|---|---|---|---|
| ១ | ប្រព័ន្ធផ្លូវ | ៥០ ខ្សែ | ឆ្នាំទី-១ | ៤៣១.២ | ផែនទីជូនភ្ជាប់ និងចំណុចនិយាមកានៅក្នុងឧបសម្ព័ន្ធ |
| ២ | ស្នាក់ការធំ និងផ្ទះស្នាក់នៅរបស់ថ្នាក់ដឹកនាំក្រុមហ៊ុន | ១០ | ឆ្នាំទី-១ | ៥ | |
| ៣ | ស្នាក់ការរង និងផ្ទះ | ១០ | ឆ្នាំទី-១ | ៥ | |

Draft

| | | | | | |
|---|---|---|---|---|---|
| | កម្មករ | | | | |
| ៤ | ប៉ុស្តិ៍យាម | ០៦ | ឆ្នាំទី-១ | - | |
| ៥ | ប៉មយាមភ្លើងឆេះព្រៃ | ២៧ | ឆ្នាំទី | - | |
| ៦ | រោងចក្រកែច្នៃ និងសំងួតពោត | ៥ | ឆ្នាំទី | ១៥ | |
| **សរុបផ្ទៃដីសំណង់ហេដ្ឋារចនាសម្ព័ន្ធ** | | | | **៤៥៦.២** | |

**៩៥.** ការចំណាយលើការសាងសង់ត្រូវបានគណនាសំរាប់អនុវត្តពីឆ្នាំទី១ ដល់ឆ្នាំទី៨ (២០០៩-២០១៦) មានដូចខាងក្រោមៈ

- ការចំណាយលើការសាងសង់សំណង់ស៊ីវិល ត្រូវបានប៉ាន់ស្មានថានឹងចំណាយរយៈពេល ០៦ឆ្នាំ ដំបូង (២០០៩-២០១៤) ដោយគ្រោងថវិកាប្រមាណ ១.៦០០.០០០ ដុល្លាអាមេរិក។ ថវិកាគ្រោងចំណាយ លើសំណង់ស៊ីវិលនេះ នឹងត្រូវប្រើប្រាស់ប្រហែល ៥០០.០០០ ដុល្លាអាមេរិកនៅឆ្នាំទី១ ទឹកប្រាក់ប្រមាណ៣០០.០០០ ដុល្លាអាមេរិកនៅឆ្នាំទី២ ទឹកប្រាក់ចំនួន ២០០.០០០ ដុល្លាអាមេរិកក្នុងមួយឆ្នាំៗ ត្រូវចំណាយនៅឆ្នាំទី៣ ដល់ឆ្នាំទី៦ (មានបង្ហាញក្នុងតារាងលំហូរសាច់ប្រាក់)។

- ថវិកាចំនួន ៥.០០០.០០០ ដុល្លាអាមេរិក គ្រោងចំណាយសំរាប់ការតំលើងរោងចក្រកែច្នៃចំនួន០១កន្លែង។

**៩៦.** ដើម្បីបំរើការងារវិនិយោគនេះ ក្រុមហ៊ុនត្រូវការប្រើប្រាស់មធ្យោបាយដឹកជញ្ជូនខ្នាតតូច និងធំ គ្រឿងចក្រ ឧបករណ៍ និងសំភារៈបរិក្ខា ដែលបំរើអោយការងារដាំដុះ ដោយក្រុមហ៊ុនគ្រោងនឹងចំណាយទឹកប្រាក់សរុប ចំនួន ១.១៧០.០០០ ដុល្លាអាមេរិក ក្នុងនោះរួមមានៈ

- ការដឹកជញ្ជូនមានរថយន្តធំ ១២ គ្រឿង រថយន្តដឹកជញ្ជូនមធ្យម (រួមទាំងរថយន្ត Pick-Up Double Cab) ចំនួន ១០ គ្រឿង។

- ការងារឈូសឆាយៈ ត្រាក់ទ័រ ០៨គ្រឿង អេស្កាវ៉ាទ័រ ០៥គ្រឿង ប៊ូលឌឺស័រចំនួន ០៣គ្រឿង សំរាប់ការងារឈូសឆាយ ត្រាក់ទ័រកៀរ-រុយដី ចំនួន ០២គ្រឿង សាក់ស័រ០៣គ្រឿង។

- ម៉ាស៊ីនភ្លើង ០៨គ្រឿង និង ម៉ាស៊ីនអារឈើចំនួន ២០គ្រឿង។

Draft

- ម៉ាស៊ីន និង មធ្យោបាយផលិតកម្មផ្សេងទៀត ដែលមានទឹកប្រាក់ ១០.០០០ ដុល្លាអាមេរិក ត្រៀមសំរាប់ទិញនៅពេលមានតំរូវការជាក់ស្តែង។

- ដើម្បីកែច្នៃផលិតផល ក្រុមហ៊ុននឹងសាងសង់រោងចក្រកែច្នៃ ០១ ដែលសរុបជាទឹកប្រាក់ចំនួនប្រមាណ ៥.០០០.០០០ ដុល្លាអាមេរិក។

សរុបចំណាយលើការទិញគ្រឿងចក្រ និង ការសាងសង់រោងចក្រមានចំនួន ៦.១៧០.០០០ ដុល្លាអាមេរិក (មានលំអិតតារាងឧបសម្ព័ន្ធ ៦-១ ក្នុងឧបសម្ព័ន្ធ៩)។

**៩៧.** ផែនការទិញគ្រឿងចក្រ ត្រូវបានគ្រោងសំរាប់រយៈពេល ០៣ឆ្នាំ គឺទឹកប្រាក់ចំនួន ៨៤០.០០០ ដុល្លាអាមេរិក ត្រូវចំណាយនៅឆ្នាំទី១ ទឹកប្រាក់ ២៨៥.០០០ ដុល្លាអាមេរិក ត្រូវចំណាយនៅឆ្នាំទី២ និង ទឹកប្រាក់ ៤៥.០០០ ដុល្លាអាមេរិក ត្រូវចំណាយនៅឆ្នាំទី៣។ សេចក្តីលំអិតនៃការចំណាយនេះ ត្រូវបានបង្ហាញជូនក្នុង ឧបសម្ព័ន្ធៈ៦-២,៣ ក្នុងផែនការមេ សូមមើលឧបសម្ព័ន្ធ៩។

### ៣-៥-៦-៥ កំលាំងពលកម្ម

**៩៨. ពលកម្មក្នុងស្រុកៈ** ក្នុងគំរោងអនុវត្តការងារវិនិយោគនេះ ក្រុមហ៊ុននឹងប្រើប្រាស់កំលាំងពលកម្មដែលមានក្នុងប្រទេស សំដៅចូលរួមចំណែកកាត់បន្ថយភាពគ្មានការងារធ្វើរបស់បុគ្គលិក និងអ្នកបច្ចេកទេសកម្ពុជា ដែលបានបណ្តុះបណ្តាលរួចពីគ្រឹះស្ថានបច្ចេកទេសនានា។ បុគ្គលិក កម្មករ អ្នកបច្ចេកទេស និងអ្នកគ្រប់គ្រង ប្រមាណ ១.០៦២ នាក់ នឹងត្រូវបានប្រើប្រាស់នៅឆ្នាំទី-១ និងកើនរហូតដល់ ១.៧៧៧ នាក់នៅឆ្នាំទី-៥ នៃការអនុវត្តន៏គំរោងនេះ ពីឆ្នាំទី-៦ ដល់ឆ្នាំទី-១០ ក្រុមហ៊ុនគ្រោងនឹងប្រើប្រាស់កំលាំងពលកម្មចំនួនជាង ១.៧០៥-១.៩០៥ នាក់ សំរាប់ការធ្វើអាជីវកម្មនេះ។

**៩៩.** ថវិកាដែលត្រូវចំណាយសំរាប់ពលកម្មក្នុងស្រុក ក្រុមហ៊ុនគ្រោងចំណាយប្រហែល ៧១២.២០០ដុល្លាអាមេរិក នៅឆ្នាំទី-១ និងកើនដល់ ១.១១៦.៨០០ដុល្លា នៅឆ្នាំទី-៥ និងទឹកប្រាក់ប្រមាណ ១.១៨៦.២០០ដុល្លា នៅឆ្នាំទី១០។ វិស្វករ និងអ្នកបច្ចេកទេសនឹងអាចទទួល ប្រាក់ខែ ៤០០ដុល្លា ក្នុង១ខែ អ្នកចាត់ចែងការគ្រប់គ្រងគំរោងវិនិយោគនេះ នឹងអាចទទួលបាន ប្រាក់ខែចំនួន ៥០០ដុល្លាអាមេរិក ក្នុង១ខែ និងចំពោះអ្នកគ្រប់គ្រងរដ្ឋបាលនឹងទទួលបាន ២០០-២៥០ ដុល្លាអាមេរិកក្នុង១ខែ។ កម្មករជំនាញធ្វើការជាអចិន្ត្រៃយ៍ ដែលមានចំនួន ៤០០-៥៨០ នាក់ គ្រោងនឹងទទួល បានប្រាក់ខែចំនួន ៨០ ដុល្លាអាមេរិក ក្នុង១ខែ និងកម្មករគ្មានជំនាញដែលជាកម្មករអណ្តែត ក្រុមហ៊ុន នឹង ជួលមកជួយធ្វើការតាមរដូវកាល មានប្រមាណ ៦០០-១.១០០នាក់ គឺអាចទទួលបាន ៥៥ ដុល្លាអា មេរិក ក្នុង១ខែ១ ផងដែរ។

១០០. ទឹកប្រាក់ធានារ៉ាប់រងសង្គម ត្រូវបានគិតប្រមាណជា ១៧ភាគរយ នៃទឹកប្រាក់ចំណាយពលកម្មសរុប ។ នៅឆ្នាំទី១ ថវិកាប្រហែល ១២១.០៧៤ ដុល្លាអាមេរិក នឹងត្រូវចំណាយលើផ្នែកនេះ និងកើនរហូតពីមួយឆ្នាំទៅមួយឆ្នាំគឺប្រមាណ១៨៩.៨៥៦ ដុល្លាអាមេរិក នៅឆ្នាំទី៥ និង ១៩៤.១៧៤ ដុល្លានៅឆ្នាំទី១០ (សេចក្តីលំអិតសូមមើលឧបសម្ព័ន្ធទី៩) ។

១០១. **ពលកម្មបរទេស:** ការងារបច្ចេកទេសក្នុងការធ្វើវិនិយោគលើការអភិវឌ្ឍន៍ផ្នែកកសិ-ឧស្សាហកម្មនេះ ទាមទារនូវជំនាញច្បាស់លាស់ក្នុងការអនុវត្តន៍ ។ ក្រុមហ៊ុនយល់ឃើញថា ថ្វីត្បិតតែយើងមានវិស្វករនិងអ្នកបច្ចេកទេសក្នុងស្រុកមួយចំនួនរួចហើយក្តី ក៏ប៉ុន្តែកិច្ចការបច្ចេកទេសនេះ ចាំបាច់ត្រូវការកំលាំងបន្ថែមពីខាងក្រៅ ដើម្បីធានាថាការងារទាំងអស់ត្រូវបានធ្វើត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស ។

១០២. កម្លាំងពលកម្មបរទេស គ្រោងនឹងជ្រើសរើសយកអ្នកជំនាញបច្ចេកទេស ដែលជាវិស្វករជំនាញ ០២រូប ឱ្យមក ជួយណែនាំក្នុងការជ្រើសរើសពូជ ការងារដាំដុះ និងថែទាំដំណាំពោតរបស់ក្រុមហ៊ុន ។ ថ្លៃឈ្នួលពលកម្មបរទេស មានកំរិតខ្ពស់គឺប្រមាណពី ១.៥០០-២.០០០ ដុល្លាអាមេរិក ក្នុង១ខែ សំរាប់បំរើការ ក្នុងគំរោងវិនិយោគនេះ ។ ថវិកាដែលត្រូវចំណាយសំរាប់ពលកម្មបរទេស គឺគ្រោងចំណាយប្រហែល ៤២.០០០ ដុល្លាអាមេរិក ក្នុងមួយឆ្នាំ នៅឆ្នាំទី១ ដល់ឆ្នាំទី៥ (ក្រុមហ៊ុនជួលអ្នកចាត់ចែងការ០១នាក់ និងវិស្វករ០១នាក់រយៈពេល០៥ឆ្នាំដំបូង) ។ នៅឆ្នាំទី-៥ ដល់ឆ្នាំទី១០ ក្រុមហ៊ុនជួលតែវិស្វករបរទេស០១នាក់ ដើម្បីជួយផ្នែកកែច្នៃពោត និងការថែទាំ ចំការពោត (មានលំអិតសូមមើលឧបសម្ព័ន្ធទី៩) ។

១០៣. **ការងារគ្រប់គ្រង-បណ្តុះបណ្តាលៈ** បុគ្គលិក-កម្មករដែលត្រូវបានទទួលការជ្រើសរើសពីក្រុមហ៊ុនរួចហើយ ក្រុមហ៊ុនមានគំរោងយកទៅបណ្តុះបណ្តាលការងារជំនាញបច្ចេកទេសបន្ថែម ក្នុងរយៈពេលពី ០១-០៣ ខែ ឬលើសពីនេះ អាស្រ័យលើការចាំបាច់ ។ ម្យ៉ាងវិញទៀត បុគ្គលិក-កម្មករ អាចមានឱកាសសិក្សារៀនសូត្រផ្ទាល់នៅឯការដ្ឋានដាំដុះជាមួយអ្នកជំនាញបច្ចេកទេសដោយអនុវត្តន៍ផ្ទាល់ ។

### ៣-៥-៦-៦ រចនាសម្ព័ន្ធនៃការគ្រប់គ្រងគំរោងវិនិយោគ

១០៤. ក្រុមហ៊ុន **អេច អិល អេច អេគ្រីខលឈ័រ (ខេមបូឌា) ខូអិលធីឌី** (HLH Agriculture (CAMBODIA) CO., LTD) មានទីស្នាក់ការកណ្តាលរបស់ខ្លួននៅផ្ទះលេខ ប៉េ ១៧ ផ្លូវផ្លេស៊ីរ សង្កាត់ស្រះចក ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ នៃព្រះរាជាណាចក្រកម្ពុជា និងមានទូរសព្ទលេខ (៨៥៥)២៣ ៩៩៥ ៥១៥ ដែលតំណាងដោយលោក Ong Beee Huat ជនជាតិសាំងហ្គាពួរ ឋានៈប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុន ។

**១០៥.** គំរោងបង្កើតកសិដ្ឋានដាំដុះដំណាំកសិ-ឧស្សាហកម្ម ពោត របស់ក្រុមហ៊ុន មានមូលដ្ឋានស្ថិតនៅក្នុងស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ (មានឧបសម្ព័ន្ធ១-២) ដែលមានទំហំ ៩.៩៨៥ ហិកតា ត្រូវបានគ្រប់គ្រងដោយក្រុមហ៊ុននេះ។ ក្នុងការគ្រប់គ្រងគំរោងវិនិយោគនេះ ក្រុមហ៊ុននឹងត្រូវធ្វើការបែងចែក ដើម្បីគ្រប់គ្រងប្រព័ន្ធការងារជា ០៤ការិយាល័យជំនាញធំៗ គឺ:

១- ការិយាល័យ កិច្ចការរដ្ឋបាល ( Administration Office): ដែលរួមមាន ផ្នែកគ្រប់គ្រងរដ្ឋបាល-បុគ្គលិក ផ្នែកគ្រប់គ្រងអចលនវត្ថុ និងផ្នែកការពារសន្តិសុខ។

២- ការិយាល័យបច្ចេកទេស (Office of Technical Affair ): ដែលរួមមានផ្នែកបច្ចេកទេស ផ្នែកគ្រប់គ្រងថ្នាល ផ្នែកកែច្នៃផលិតផល ផ្នែករោងជាង និងកិច្ចការពិនិត្យគុណភាពរោងជាង .....។

៣- ការិយាល័យ ផែនការ គណនេយ្យ-ហិរញ្ញវត្ថុ (Office of Planning, Accounting and Finance): ដែលរួមមានផ្នែកធ្វើផែនការ និងចាត់តាំងគ្រប់គ្រងកំលាំងពលកម្មកិច្ចការគណនេយ្យ- ហិរញ្ញវត្ថុ។

៤- ការិយាល័យ ទីផ្សារ និងការនាំចេញ (Office of Marketing & Export): ដែលរួមមានផ្នែកគ្រប់គ្រងការលក់ផលិតផល ផ្នែកម៉ាឃីតធីង-ទំនាក់ទំនងទីផ្សារ និងផ្នែកគ្រប់គ្រងការនាំចេញ-នាំចូល ។

**១០៦.** រចនាសម្ព័ន្ធគ្រប់គ្រងរបស់គំរោងវិនិយោគនេះ មានបង្ហាញជូនក្នុងអង្គការលេខខាងក្រោម:



## ៣-៦ ការវិភាគសេដ្ឋកិច្ចនៃតំបន់គំរោងវិនិយោគ

### ៣-៦-១ ទុនវិនិយោគ និងការវិភាគលំហូរសាច់ប្រាក់

#### ៣-៦-១-១ ទុនសំរាប់វិនិយោគ

១០៧. ដើម្បីដំណើរការងារវិនិយោគនេះ ក្រុមហ៊ុនចំរុះ **អេច អិល អេច អេគ្រីខលឈ័រ (ខេមបូឌា) ខូអិលធីឌី** និងត្រូវការដើមទុនប្រមាណ ៤០,០០,០០០ ដុល្លាអាមេរិក សំរាប់ចំណាយលើការដាំដុះដំបូង ការសាងសង់សំណង់ស៊ីវិល ចំណាយលើការទិញមធ្យោបាយផលិតកម្ម និងចំណាយប្រតិបត្តិការអាជីវកម្មក្នុងដំណាក់កាល ១០ ឆ្នាំដំបូងនៃការអភិវឌ្ឍន៏និងអាជីវកម្មដាំដុះក្នុងកសិដ្ឋាននេះ។ ទុនវិនិយោគត្រូវបានបែងចែកតាមខ្ទង់ចំណាយដូចខាងក្រោម :

**តារាង ៣-៦ : តារាងបញ្ជាក់ពីចំនួន ប្រភេទ ផ្ទៃដីសំណង់**

| **ទុនវិនិយោគតាមមុខចំណាយ** | | **ទឹកប្រាក់ គិតជាដុល្លាអាមេរិក** |
|---|---|---|
| ទុនសំរាប់ការងារដាំដុះដំបូង | Plantation Devevopment | ៨,៧១៨,៩៧០ |
| ទុនសំរាប់សំណង់ស៊ីវិល | Civil Work | ១,៦០០,០០០ |
| ទុនសំរាប់ការកសាងរោងចក្រកែច្នៃ | Factory | ១៥,០០០,០០០ |
| ទុនសំរាប់គ្រឿងចក្រ | Heavy Equipment | ១,១៧០,០០០ |
| ទុនសំរាប់ការំណាយលើទព្វសំភារៈ ការិយាល័យ | Office Equipment | ៣៣,៥៥០ |
| ទុនសំរាប់ចំណាយប្រតិបត្តិការអាជីវកម្ម | Recurrent Costs | ២១,៧១២,៤០០ |
| **ទុនវិនិយោគសរុប Total Investment Capital (US$)** | | **៤០,០០០,០០០** |

១០៨. ដើមទុនដែលមានសមមាត្រច្រើនជាងគេ គឺទុនសំរាប់ការចំណាយលើប្រតិបត្តិការ អាជីវកម្មដាំដុះដែលមានប្រមាណ ៧០ ភាគរយនៃដើមទុនសរុប។ ដើមទុនសំរាប់ការងារដាំដុះដំបូង គ្រោងចំណាយប្រមាណ ១៦ភាគរយ ទុនសំរាប់ការទិញគ្រឿងចក្រ ៣ ភាគរយ ទុនសំរាប់ការដំឡើងរោងចក្រ ៩ភាគរយ ទុនសំរាប់ការសាងសង់សំណង់ស៊ីវិល ៣ ភាគរយ និងទុនសំរាប់ការទិញទព្វសំភារៈការិយាល័យជិត ១ ភាគរយ។ ក្រាហ្វិកខាងក្រោមនេះ គឺបង្ហាញច្បាស់អំពីការប្រើប្រាស់ទុនវិនិយោគតាមផ្នែកចំណាយនិមួយៗ។




### ៣-៦-១-២ ការចំណាយសំរាប់រយៈពេល២០ឆ្នាំ

១០៩. ថវិកាដែលត្រូវវិនយោគលើគំរោងផលិតកម្ម ដំណាំកសិកម្ម-ឧស្សាហកម្ម ដំណាំពោត និងការចំណាយលើការកែច្នៃរយៈពេល ១០ឆ្នាំដំបូង ២០០៩-២០១៨ គ្រោងនឹងចំណាយសុទ្ធអស់ចំនួន ៤៩,៩០០,៤១០ ដុល្លាអាមេរិក។ ថវិកាដែលត្រូវចំណាយសំរាប់ប្រតិបត្តិការ ក្នុងគំរោងវិនិយោគនេះមានចំនួន៣៦.៧១២.៤០០ ដុល្លាអាមេរិក ដែលរួមមាន ចំណាយលើកំលាំងពលកម្ម ការដាំដុះ ការថែទាំដំណាំ ការប្រមូលផល ដឹងជញ្ជូន ចំណាយលើដំណើរការរោងចក្រកែច្នៃ និងចំណាយលើការដាំដុះជួសថ្មីឡើងវិញ។ ថវិកាសំរាប់ចំណាយលើការដាំដុះដំបូង ត្រូវបានគ្រោង ប្រហែល ៨,៧១៨.៥៧០ ដុល្លាអាមេរិក និងទឹកប្រាក់ចំនួន ៤,៤៦៩,៤៤០ ដុល្លាអាមេរិក សំរាប់ចំណាយថេរមិនមែនពន្ធ។




Draft

## តារាង ៣-៧ ៖ តារាងចំណាយនៃការដាំដុះ-កែច្នៃ រយៈពេល ២០ ឆ្នាំដំបូង

| បណ្ដាឆ្នាំ | | ទឹកប្រាក់ចំណាយតាមឆ្នាំ និមួយៗ |
|---|---|---|
| ចំណាយឆ្នាំទី-១ | : | ៣.៤៣៥.៣៧៦ |
| ចំណាយឆ្នាំទី-២ | : | ៣.៥៧៦.៦៧៨ |
| ចំណាយឆ្នាំទី-៣ | : | ៤.៥៦៣.៩៣៤ |
| ចំណាយឆ្នាំទី-៤ | : | ៤.៦៧៨.៥៩៤ |
| ចំណាយឆ្នាំទី-៥ | : | ៥.០២១.៧៨៨ |
| ចំណាយឆ្នាំទី-៦ | : | ៣.២៥៦.៤៤៦ |
| ចំណាយឆ្នាំទី-៧ | : | ៤.៧៩៤.១៧៤ |
| ចំណាយឆ្នាំទី-៨ | : | ៥.២៩៤.៨៧៤ |
| ចំណាយឆ្នាំទី-៩ | : | ៦.៥៣៦.២៧៤ |
| ចំណាយឆ្នាំទី-១០ | : | ៨.៧៤២.២៧៤ |
| ចំណាយឆ្នាំទី-១១ | : | ១០.៣៨៩.៤៧៤ |
| ចំណាយឆ្នាំទី-១២ | : | ១០.៣៧៩.៤៧៤ |
| ចំណាយឆ្នាំទី-១៣ | : | ១០.៣៧៩.៤៧៤ |
| ចំណាយឆ្នាំទី-១៤ | : | ១០.៣៧៩.៤៧៤ |
| ចំណាយឆ្នាំទី-១៥ | : | ១០.៣៧៩.៤៧៤ |
| ចំណាយឆ្នាំទី-១៦ | : | ១០.៣៧៩.៤៧៤ |
| ចំណាយឆ្នាំទី-១៧ | : | ១០.៣៧៩.៤៧៤ |

Draft

ចំណាយឆ្នាំទី-១៨ : ១០.៣៧៩.៤៧៤

ចំណាយឆ្នាំទី-១៩ : ១០.៣៧៩.៤៧៤

ចំណាយឆ្នាំទី-២០ : ១០.៣៧៩.៤៧៤

### ៣-៦-១-៣ ការវិភាគលំហូរសាច់ប្រាក់

**១១០.** យោងតាមការគណនាលំហូរសាច់ប្រាក់របស់ក្រុមហ៊ុន (Cash Flow Projection) ដូចដែលបានរៀបរាប់លំអិតឧបសម្ព័ន្ធ-២ក(ក្នុងឧបសម្ព័ន្ធទី៩) បង្ហាញថា ចាប់ពីឆ្នាំទី១ (២០០៩) សមតុល្យសាច់ប្រាក់អវិជ្ជមាន (-) បានកើតមានឡើងរហូតដល់ឆ្នាំទី៩ (២០១៧) គឺប្រមាណពី -៤.៧១៩.៣៣៤ ដុល្លាអាមេរិក នៅឆ្នាំទី១ (គឺជាការអភិវឌ្ឍន៍លើការបង្កើតកសិដ្ឋាន ការទិញគ្រឿងចក្រ និងជាពិសេសការចំណាយលើសំណង់ស៊ីវិល) -៤.១២៧.៥៨៦ ដុល្លាអាមេរិក នៅឆ្នាំទី២ -៤.៦៨៦.៣៤២ ដុល្លាអាមេរិក នៅឆ្នាំទី៣។ នៅឆ្នាំទី៤-៧ លំហូរសាច់ប្រាក់ កើនខ្ពស់គឺពី -៤.៧៥៦.០០២ នៅឆ្នាំទី៤ ដល់-៥.៣៤៩.១៩៦ ដុល្លាអាមេរិក នៅឆ្នាំទី៥ -៤.៥៨៣.៨៥៤ ដុល្លាអាមេរិក នៅឆ្នាំទី៦ និងប្រមាណ -៥.០៧៨.៥២៤ ដុល្លាអាមេរិក នៅឆ្នាំទី៧ (កើនខ្លាំងដោយសារការចំណាយលើសំណង់រោងចក្រកែច្នៃ)។ និងនៅឆ្នាំទី៨ លំហូរសាច់ប្រាក់ (-) មានប្រហែលតែ ២.៧ លានដុល្លាអាមេរិក។ នៅឆ្នាំទី៩ ចំណាយនឹងថយចុះជាបន្តបន្ទាប់គឺជាង -៦៦៧.៤៧៤ ដុល្លាអាមេរិក។

Draft

**១១១.** ចាប់ពីឆ្នាំទី១០ទៅ លំហូរសាច់ប្រាក់វិជ្ជមាន (+) បានចាប់ផ្តើមកើនពី ៧៩៧.៩៧៦ ដុល្លាអាមេរិក (នៅឆ្នាំទី១០) រហូតដល់ ៤.៩១៣.៨០១ ដុល្លាអាមេរិក នៅឆ្នាំទី១៣។ ការកើនឡើងនៃលំហូរសាច់ប្រាក់វិជ្ជមាន (+) គឺ អាស្រ័យដោយសាច់ប្រាក់ ដែលប្រមូលបានមកវិញពីការវិនិយោគ មានទំហំធំចាប់ពីឆ្នាំទី១០ ពីជាង ១០.១៩ លានដុល្លាអាមេរិក រហូតដល់ជាង ១៦.៥៨ លាន ដុល្លាអាមេរិក នៅឆ្នាំទី១៣។

## ៣-៦-២ របាយការណ៍ចំណូល និងចំណេញ-ខាត

### ៣-៦-២-១ របាយការណ៍ចំណូល

**១១២.** ផលិតកម្មដំណាំពោត ត្រូវបានប៉ាន់ស្មានថា នឹងទទួលបានទិន្នផលដំបូង (ឆ្នាំទី-១-៣) ប្រមាណ ៣ តោនក្នុងមួយហិកតា និងទិន្នផលកើនរហូតចាប់ពី ឆ្នាំទី-៤-២០ ដល់ ៦ តោនក្នុងមួយហិកតា។

**១១៣.** ការប៉ាន់ស្មានប្រាក់ចំណូលគិតជាដុល្លាអាមេរិក ដែលបានមកពីការលក់ដំរពោត នៅតាមឆ្នាំនីមួយៗ មានភាពខុសៗគ្នា អាស្រ័យទៅតាមចំនួនដើមពោត ដែលដាំដុះលើផ្ទៃដីត្រូវបានពង្រីក ពីមួយឆ្នាំទៅមួយឆ្នាំ

ច្រើនឡើង១ដែរ។ រយៈពេលដែលអាចចាប់ផ្តើមអោយផល គឺនៅឆ្នាំ ២០០៩ ( រយៈពេល០.៥ឆ្នាំ ចាប់ពីពេលដាំក្នុងចំការ) ។

**១១៤.** ក្រៅពីនេះតំលៃពោតជាកត្តាសំខាន់ ក្នុងការប៉ាន់ស្មានរកប្រាក់ចំណូល នៃគំរោងដាំដុះធ្វើអាជីវកម្មដំណាំពោតនេះដែរ។ តាមនិន្នាការតំលៃទីផ្សារអន្តរជាតិ ដែលក្រុមហ៊ុនដាំពោតមួយចំនួនបាននាំចេញទៅលក់ នៅក្រៅប្រទេសពីឆ្នាំ ២០០០-២០០៦ ឃើញថាមានការប្រែប្រួលតែ ៥-៦% ប៉ុណ្ណោះ។ នៅឆ្នាំ ២០០៤ តំលៃពោតបានឡើងដល់ ១៨០ ដុល្លាអាមេរិកក្នុងមួយតោន។

**១១៥.** តាមការគណនាផលិតផលពោតក្នុង(ឧបសម្ពន្ធ័ទី៩ មើលឧបសម្ព័ន្ធ៤-ក) បានបង្ហាញថា នៅឆ្នាំទី៧ ផលិតកម្មដំណាំពោតអាចផ្តល់បរិមាណផលសរុបបាន ១.១១០ តោន ហើយកើនរហូតពីមួយឆ្នាំទៅមួយឆ្នាំ តាមទំហំផ្ទៃដីអាជីវកម្ម ដល់ ៧.៩៥០ តោន នៅឆ្នាំទី១០ (២០១៨) នៅឆ្នាំទី១១-១២ ផលិតផលពោតទទួលបានក្នុងចន្លោះ ១១.៣៤០-១២.២៨៥ តោន។ ចន្លោះឆ្នាំទី១៣-១៤ ផលិតផលពោត ទទួលបានប្រហែល ១៣.៣៣០-១៤.១៧៥តោន ក្នុង១ឆ្នាំ។ តំលៃលក់ផលិតផល ពោតត្រូវបានប៉ាន់ស្មាន ជ ាមធ្យមប្រហែល ១.៣៥០ ដុល្លាអាមេរិក ក្នុង១តោន សំរាប់គណនាចំណូលក្នុងផែនការមេនេះ។

ចំណូលបានមកពីការលក់ពោត នឹងអាចទទួលបាននៅឆ្នាំ២០០៩ ប្រហែល ១.៤៩៨.៥០០ ដុល្លាអាមេរិក និងកើនជាបន្តបន្ទាប់ពីមួយឆ្នាំទៅមួយឆ្នាំរហូតដល់ ១០.១៩២.៥០០ ដុល្លាអាមេរិកនៅក្នុងឆ្នាំទី១០ (២០១៨)។ ចាប់ពីឆ្នាំទី១១-១៥ បរិមាណចំណូលបានកើនឡើងក្នុងរង្វង់ពី ជាង ១៥.៣ លានដុល្លាអាមេរិក ដល់ជាង ១៩.១៣ លានដុល្លាអាមេរិក និងបានកើនខ្លាំងនៅឆ្នាំ ទី១៦-២០ (២០២៤-២០២៨) គឺប្រមាណជា ២០.៤១លានដុល្លាអាមេរិក។

**តារាង ៣-៨ : តារាងចំណូលពីការវិនិយោគ ពីឆ្នាំទី-១ ដល់ ឆ្នាំទី-២០**

| បណ្តាឆ្នាំ | | ទឹកប្រាក់ចំណូល (USD) |
|---|---|---|
| ចំណូលឆ្នាំទី-១ | : | - |
| ចំណូលឆ្នាំទី-២ | : | - |
| ចំណូលឆ្នាំទី-៣ | : | - |
| ចំណូលឆ្នាំទី-៤ | : | - |

Draft

| | | |
|---|---|---|
| ចំណូលឆ្នាំទី-៥ | : | - |
| ចំណូលឆ្នាំទី-៦ | : | - |
| ចំណូលឆ្នាំទី-៧ | : | ១.៤៩៨.៥០០ |
| ចំណូលឆ្នាំទី-៨ | : | ៣.៥៤៣.៧៥០ |
| ចំណូលឆ្នាំទី-៩ | : | ៦.១០២.០០០ |
| ចំណូលឆ្នាំទី-១០ | : | ១០.១៩២.៥០០ |
| ចំណូលឆ្នាំទី-១១ | : | ១៥.៣០៩.០០០ |
| ចំណូលឆ្នាំទី-១២ | : | ១៦.៥៨៤.៧៥០ |
| ចំណូលឆ្នាំទី-១៣ | : | ១៦.៥៨៤.៧៥០ |
| ចំណូលឆ្នាំទី-១៤ | : | ១៧.៨៦០.៥០០ |
| ចំណូលឆ្នាំទី-១៥ | : | ១៩.១៣៦.២៥០ |
| ចំណូលឆ្នាំទី-១៦ | : | ២០.៤១២.០០០ |
| ចំណូលឆ្នាំទី-១៧ | : | ២០.៤១២.០០០ |
| ចំណូលឆ្នាំទី-១៨ | : | ០.៤១២.០០០ |
| ចំណូលឆ្នាំទី-១៩ | : | ២០.៤១២.០០០ |
| ចំណូលឆ្នាំទី-២០ | : | ២០.៤១២.០០០ |

Draft

**៣-៦-២-២ របាយការណ៍ចំណេញ-ខាត**

**១១៦.** របាយការណ៍ចំណេញ-ខាត ពីឆ្នាំទី១ ដល់ឆ្នាំទី២០ ត្រូវបានបង្ហាញលំអិតក្នុង (ឧបសម្ព័ន្ធ-៩) ។ ទំហំផ្ទៃដីដាំដុះបានប្រែប្រួលក្នុងចន្លោះពី ១.៨៥០ ហិកតា ដល់ ១.៩០០ ហិកតា ក្នុងរយៈពេល ០៥ ឆ្នាំដំបូង ។

យោងលើរបាយការណ៍ ចំណូល និងចំណេញ-ខាត បានបង្ហាញថា របាយការណ៍ខាត (-) កើតមានឡើងចាប់ពីឆ្នាំទី១ រហូតដល់ឆ្នាំទី៩។ ទឹកប្រាក់ចំនួន ៣.៤៣៥.៣៧៦ ដុល្លាអាមេរិក គឺជាការខាតបង់នៅឆ្នាំទី១ និងកើនរហូតដល់ជាង ៥.០២១.៧៨៨ ដុល្លាអាមេរិក នៅឆ្នាំទី៥។ នៅឆ្នាំទី៦-៧ ការចំណាយមានការប្រែប្រួលពី ៣.២៥៦.៤៤៦ ដុល្លាអាមេរិក ដល់ ៣.៤៤៥.៥២៤ ដុល្លាអាមេរិក នៅឆ្នាំទី៧។ របាយការណ៍ខាត មានការថយចុះជាបន្តបន្ទាប់ពីឆ្នាំទី ៨-៩ ចន្លោះ ពី ២.១០៥.៤៤៩ លានដុល្លាអាមេរិក នៅឆ្នាំទី៨ មកត្រឹម ១.០៤៤.៤៧៤ ដុល្លាអាមេរកនៅឆ្នាំទី៩។

**១១៧.** ការចំណាយដូចបានគណនាក្នុងរបាយការណ៍ចំណូល និងចំណេញ-ខាត ក្នុងឧបសម្ព័ន្ធ៩ ត្រូវបានគណនាឃើញដូចខាង ក្រោម៖

**តារាង ៣-៩ ៖ តារាងចំណូលពីការវិនិយោគ ពីឆ្នាំទី-១ ដល់ ឆ្នាំទី-១៥**

| | | |
|---|---|---|
| របាយការណ៍ខាតឆ្នាំទី-១ | : | -៣.៤៣៥.៣៧៦ US$ |
| របាយការណ៍ខាតឆ្នាំទី-២ | : | -៣.៥៧៦.៦៧៨ US$ |
| របាយការណ៍ខាតឆ្នាំទី-៣ | : | -៤.៥៦៣.៩៣៤ US$ |
| របាយការណ៍ខាតឆ្នាំទី-៤ | : | -៤.៦៧៨.៥៩៤ US$ |
| របាយការណ៍ខាតឆ្នាំទី-៥ | : | -៥.០២១.៧៨៨ US$ |
| របាយការណ៍ខាតឆ្នាំទី-៦ | : | -៣.២៥៦.៤៤៦ US$ |
| របាយការណ៍ខាតឆ្នាំទី-៧ | : | -៣.៤៤៥.៥២៤ US$ |
| របាយការណ៍ខាតឆ្នាំទី-៨ | : | -២.១០៥.៤៩៩ US$ |
| របាយការណ៍ខាតឆ្នាំទី-៩ | : | -១.០៤៤.៤៧៤ US$ |
| របាយការណ៍ខាតឆ្នាំទី-១០ | : | ៤៣០.៩៧៦ US$ |
| របាយការណ៍ខាតឆ្នាំទី-១១ | : | ៣.៣៨៨.៦២៦ US$ |
| របាយការណ៍ខាតឆ្នាំទី-១២ | : | ៤.៥៤៦.៨០១ US$ |
| របាយការណ៍ខាតឆ្នាំទី-១៣ | : | ៤.៥៤៦.៨០១ US$ |
| របាយការណ៍ខាតឆ្នាំទី-១៤ | : | ៥.៦៩៤.៩៧៦ US$ |
| របាយការណ៍ខាតឆ្នាំទី-១៥ | : | ៦.៨៤៣.១៥១ US$ |

**១១៨.** ប្រាក់ចំណូលសុទ្ធ (Net Income/Profit) ត្រូវបានប៉ាន់ស្មានថានឹងទទួលបានចាប់ពីឆ្នាំទី១០ ចំនួន ៤៣០.៩៧៦ ដុល្លាអាមេរិក។ នៅឆ្នាំទី១១ ប្រាក់ចំណេញសុទ្ធទទួលបានប្រហែល ៣.៣៨ ដុល្លាអាមេរិក នៅឆ្នាំ

Draft

ទី១២ ទទួលបានប្រហែល ៤.៥៤ លានដុល្លាអាមេរិក និង ទឹកប្រាក់ចំនួន៧.៩៩លាន ដុល្លាអាមេរិក ជាទឹកប្រាក់ទទួល នៅឆ្នាំទី២០។

### ៣-៦-៣ ប្រសិទ្ធភាពនៃគំរោងវិនិយោគ

**១១៩.** យោងតាមរបាយការណ៍វិភាគសេដ្ឋកិច្ចអាជីវកម្មរបស់ក្រុមហ៊ុន បានបង្ហាញអំពីលំហូរសាច់ប្រាក់សុទ្ធ ដែលនិងចាប់ផ្តើមប្រតិបត្តិការពីឆ្នាំ ២០០៩ រហូតដល់ឆ្នាំ២០២៨ រយៈពេល២០ឆ្នាំ ក្នុងការអនុវត្តន៍គំរោង ការដាំដុះ និងអាជីវកម្ម គឺបង្ហាញថា: លំហូរសាច់ប្រាក់មានការប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ អាស្រ័យទៅលើ ការបណ្តាក់ទុន និងចំណូលចំណាយលើកិច្ចប្រតិបត្តការហិតរញ្ញវត្ថុនៃឆ្នាំនិមួយៗ។ ទិន្នន័យសំរាប់ធ្វើការវិភាគ ប្រសិទ្ធភាពសេដ្ឋកិច្ច-ហិរញ្ញវត្ថុក្នុងផែនការមេនេះ គឺផ្អែកលើលំហូរសាច់ប្រាក់សុទ្ធ (មានលំអិតក្នុង ឧបសម្ពន្ធ៩)។

**១២០.** ម្យ៉ាងវិញទៀត អនុលោមទៅតាមទ្រឹស្តីវិនិយោគទុន អាត្រាការប្រាក់ ឬអត្រាអប្បហារ ត្រូវបាន យកមកគណនានៅក្នុង ការរកប្រសិទ្ធភាពហិរញ្ញវត្ថុ នៃគំរោងវិនិយោគ។ បច្ចុប្បន្នអត្រាការប្រាក់តាមបណ្តុ ធនាគា ពាណិជ្ជកម្មនានា មានការខុសគ្នាបន្តិចបន្តួចប៉ុរែប៉ុរួលពី ៣% ទៅ ៦% ក្នុងមួយឆ្នាំ ក្នុងប្រភេទគណនីមាន ការកំណត់។

**១២១.** ក្រុមហ៊ុនធ្វើការវិភាគភាពរឹងប៉ឹងនៃគំរោងវិនិយោគ តាមការគណនាតម្លៃបច្ចុប្បន្ន (Present Value) នៃលំហូរសាច់ប្រាក់រយៈពេល ២០ឆ្នាំ ដោយកំណត់អត្រា Marginal Cost of Capital (Discounted Rate) ស្មើនឹង ៨% ការគណនា តម្លៃបច្ចុប្បន្នសុទ្ធ (Net Present Value or NPV) និងការគណនា Internal Rate of Retum (IRR)។ លទ្ធផលនៃការគណនាបានបង្ហាញជូនដូចខាងក្រោម :

- តម្លៃបច្ចុប្បន្ន (Present Value)= ២៦.៤៣៥.៣៤៦ ដុល្លាអាមេរិក ក្រុមហ៊ុនត្រូវការដើមទុន អាជីវកម្ម សំរាប់ ០៩ឆ្នាំដំបូង គឺប្រមាណ ២៦.៤៣ លានដុល្លាអាមេរិក ប្រសិនបើអត្រាអប្បហា Discounted Rate=៨%។
- តម្លៃបច្ចុប្បន្នសុទ្ធ (Net Present Value or NPV) = ៣១.៤១៧.២០៩ លានដុល្លាអាមេរិក : តម្លៃបច្ចុប្បន្នសុទ្ធនៃគំរោងវិនិយោគនេះ ជាចំនួនវិជ្ជមាន ដែលក្រុមហ៊ុនអាចសន្និដ្ឋានបានថា ការធ្វើអាជីវកម្ម មានដំណើរការល្អ និងទទួលយកបាន។
- ការគណនា Intenal Rate of Retum (IRR) = ១៤% : តួលេខនេះគឺធ្វើឱ្យក្រុមហ៊ុន អាចមាន ក្តីសង្ឃឹមច្រើន ក្នុងការធ្វើអាជីវកម្មរបស់ខ្លួន ព្រោះ Intenal Rate of Retum(IRR) មានទំហំ ធំរហូតដល់ ១៤ភាគរយ នៅពេលដែល Discunted Rate កំណត់ត្រឹម ០៨%។

Draft

- រយៈពេលប្រមូលទុនមកវិញ (Payback Period): នៅក្នុងរង្វង់រយះពេល ១៦ឆ្នាំ ក្រុមហ៊ុន អាចមានលទ្ធភាពទូទាត់សង និងប្រមូលមកវិញ នូវដើមទុនវិនិយោគនៃគំរោង អាជីវកម្មនេះ។
- សន្ទស្សន៍ផលចំណេញ (Profitability Index or Benefir/Cost Ratio) ក្នុងរយះពេល ២០ដំបូងនេះ ត្រូវបានគណនាឃើញ ប្រហែល ១.៣៦។ គំរោងវិនិយោគនេះ អាចទទួលយកបាន ព្រោះសនស្សន៍ផលចំណេញ ធំជាង ០១ ឫអាចនិយាយ បានថា ១ដុល្លាអាមេរិក ដែលត្រូវបាន វិនិយោគនឹងអាចបង្កើន តម្លៃបាន ០.៣៦ ដុល្លាអាមេរិក។ (សូមមើលរបាយការណ៍លំអិតមាន ក្នុងឧបសម្ព័ន្ធ-៩)